# ការវិភាគតុលាការគំរូកម្ពុជា

*ដំណាក់កាលរឿងក្តីទាំង១០ដំណាក់កាល- ទិសដៅ-ស្តង់ដា- គោលការណ៍/ លក្ខណៈវិនិច្ឆ័យ*

*(ការពិភាក្សាថ្ងៃទី ៥-៨ វិច្ឆិកា ២០០៧ និងថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨)*

*រៀបចំដោយក្រុមការងារបច្ចេកទេសតុលាការគំរូកម្ពុជានិងបានអនុម័តដោយក្រុមការងារជាន់ខ្ពស់តុលាការគំរូកម្ពុជា*

*ភ្នំពេញ ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ២០០៨*

# អំណត់បន្ថាញ

អំណាចតុលាការ ជាអំណាចមួយក្នុងបណ្តាអំណាចទាំងបីថែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

អំណាចតុលាការនេះ ជាអំណាចឯករាជ្យគ្របដណ្តប់ទៅលើរឿង ក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។

អំណាចនេះត្រូវប្រគល់អោយតុលាការកំពូល និងសាលាជំនុំជំរះក្តីគ្រប់ផ្នែក និងគ្រប់ជាន់ថ្នាក់។

តាមរចនាសម្ពន្ធ័សព្វថ្ងៃសាលាជំនុំជំរះក្តីគ្រប់ផ្នែកទាំងនៅទីក្រុងភ្នំពេញមាន តុលាការកំពូល និងសាលឧទ្ធរណ៍ ទាំងនៅតាមខេត្ត និងក្រុងនានានៃ ព្រះរាជាណាចក្រកម្ពុជាមាន សាលាដំបូង។ នៅអមសាលាជំនុំជំរះក្តីនីមួយៗ មានអង្គការអយ្យការ ហើយមានតែអង្គការនេះទេដែលមាន សិទ្ធិធ្វើបណ្តឹងអាជ្ញា។

សាលាជំនុំជំរះក្តី និងអង្គការអយ្យការស្ថិតនៅក្នុងបរិវេណតែមួយ។ ច្បាប់នីតិវិធីរដ្ឋប្បវេណី និងច្បាប់នីតិវិធីព្រហ្មទ័ណ្ឌដែលចូលជាធរមានសព្វថ្ងៃបានបង្ហូរចេញមកនូវវិធានគ្រប់គ្រងដូចតទៅ :

## I. ផ្នែកសាលាជំនុំជំរះក្តី

### - ផ្នែករឿងរដ្ឋប្បវេណី

ស្មារតីច្បាប់ទាំងពីរនេះបានប្រគល់ការគ្រប់គ្រងរដ្ឋបាលទូទៅ ការគ្រប់គ្រងដំណើររឿងក្តីទាំង ១០ ដំណាក់កាលទៅប្រធាន សាលាជំរះក្តី ឬហៅថា ប្រធានតុលាការ។ ដោយឡែកអង្គការអយ្យការ ឬស្ថាប័នអយ្យការដែលនៅអមសាលាជំនុំជំរះក្តី មានភារៈកិច្ចតែនៅក្នុងដំណាក់កាលជំនុំជំរះ និងដំណាក់កាល សម្រេចសេចក្តី ( Hearing of the case and the Decision of the Case ) ដើម្បីការពារផលប្រយោជន៍អនីតិជន អសមត្ថជន និងសណ្តាប់ធ្នាប់សាធារណៈ (Ordre Publique) ប៉ុណ្ណោះ។

- ផ្នែករឿងព្រហ្មទណ្ឌ

សាលាជំនុំជំរះក្តី ឬតុលាការព្រហ្មទណ្ឌ គ្រប់គ្រងដំណើររឿងក្តីចាប់ពីដំណាក់កាល រៀបចំសំណុំរឿងចប់ បានន័យថា ក្រោយពីរៀបចំសំណុំរឿងចប់ អង្គការ អយ្យការ ឬចៅក្រមស៊ើបសួរធ្វើសេចក្តីសន្និដ្ឋាន ឬដីការសម្រេចប្តឹងទៅសាលាជំនុំជំរះក្តីអោយធ្វើការជំនុំជំរះ ។

នៅដំណាក់កាលជំនុំជំរះក្តី វត្តមានរបស់តំណាងអង្គការអយ្យការមានភាពចាំបាច់ បានន័យថាបើនៅពេលជំនុំជំរះនោះ ពុំមានវត្តមានតំណាងអង្គការ អយ្យការទេនោះការសំរេចសេចក្តីត្រូវចាត់ទុកជាមោឃៈ ។

## II. ផ្នែកអង្គការអយ្យការដែលនៅអមសាលាជំនុំជំរះក្តី

អង្គការនេះគ្រប់គ្រងរដ្ឋបាលទូទៅដោយព្រះរាជអាជ្ញាមួយរូប ហើយមិនស្ថិតនៅក្រោមរដ្ឋបាលទូទៅ របស់ប្រធានសាលាជំនុំជំរះក្តី ឬប្រធានតុលាការ ឡើយ ប៉ុន្តែគ្រប់គ្រងដំណើររឿងក្តីផ្នែកព្រហ្មទណ្ឌសុទ្ធសាធលើបីដំណាក់កាល ចាប់ពីដំណាក់កាលទី១ រហូតដល់ដំណាក់កាលទី៣ ដំណាក់កាលបន្តទៅទៀត តាមសេចក្តីសន្និដ្ឋាន ឬដីការសំរេចត្រូវបញ្ជូនសំណុំរឿងទៅអោយ ប្រធានសាលាជំនុំជំរះក្តី ហើយត្រូវមានវត្តមានចាំបាច់ក្នុង ដំណាក់កាល ជំនុំជំរះរឿងក្តីព្រហ្មទណ្ឌ។

ជាសេចក្តីសន្និដ្ឋាន បើពិនិត្យមើលទំនាក់ទំនងការងាររវាងអង្គការទាំងពីរនេះឃើញថា ដើម្បីឈានទៅកាន់ការ សម្រេចសេចក្តីរឿងក្តីព្រហ្មទណ្ឌនីមួយៗ វាទាមទារអោយមានវត្តមានអង្គការទាំងពីរ ។

ដូចនេះការធ្វើកំណែទម្រង់តុលាការមានន័យថា ធ្វើក្នុងក្របខ័ណ្ឌនៃអង្គការទាំងពីរ ។

## ដំណាក់កាលនៃដំណើររឿងក្តី

### ដំណាក់កាលទី១. ការទទួលប្រជាពលរដ្ឋ/រឿងក្តី

| ប្រភេទរឿងក្តី | ទិសដៅ | ស្តង់ដា | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់ និង បទបញ្ញត្តិជាតិ | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់ និង បទបញ្ញត្តិអន្តរជាតិ |
|---|---|---|---|---|
| **ទូទៅ** | - តុលាការ ត្រូវតែជាកន្លែង ដែលប្រជាពលរដ្ឋ អាចប្រើប្រាស់បាន<br>- តុលាការ មានដំណើរការប្រកបដោយតម្លាភាព<br>- ចៅក្រមសម្រេចសេចក្តីដោយឯករាជ្យ<br>- ចៅក្រម ព្រះរាជអាជ្ញា មេធាវី និងមន្ត្រីតុលា ការ ត្រូវមានជំនាញវិជ្ជាជីវៈ និងមានការយល់ ដឹងគ្រប់គ្រាន់<br>- មន្ត្រីតុលាការ បម្រើការងារ ដោយគោរពក្រម សីលធម៌<br>- ដំណើរការតុលាការ ត្រូវបានធ្វើឡើងដោយមិន លំអៀង យុត្តិធម៌ និងប្រកបដោយវិជ្ជាជីវៈ<br>-តុលាការមានដំណើរការប្រកប | **ស្តង់ដាទី5 :** តុលាការមាន សមត្ថកិច្ច | -តុលាការមានបុគ្គលិកដែលមានសមត្ថភាពដែលអាច ទទួលពាក្យបណ្តឹងប្រជាពលរដ្ឋបាន ( ក្រម នីតិវិធីព្រហ្ម ទណ្ឌមាត្រា ៤ និងមាត្រា ៥)<br>-តុលាការមានបុគ្គលិកដែលមានសមត្ថភាព អាចវាយ តម្លៃលើពាក្យបណ្តឹងរបស់ ប្រជាពលរដ្ឋ ថាតើពាក្យបណ្តឹង នោះត្រូវនឹងយុត្តាធិការរបស់តុលាការ ( ក្រមនីតិវិធី រដ្ឋប្បវេណី មាត្រា ៧-២២)<br>-តុលាការត្រូវបានរៀបចំឡើង ដើម្បីឱ្យពាក្យបណ្តឹង របស់ប្រជាពលរដ្ឋអាចចុះ បញ្ជី និងអាចតាមដានបាន ( ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥0 និង មាត្រា ៧៥ , និងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦)<br>-តុលាការមានបុគ្គលិកដែលមានសមត្ថភាព អាចចាត់ចែងរឿងក្តី ដើម្បីកំណត់ បញ្ហាឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ ( ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៤៧-៣៦៤ និងក្រមនីតិវិធីរដ្ឋប្បវេណី គន្ថី ទី ២ ជំពូកទី ៥ : ការសម្រេចសេចក្តី) | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធមនុស្ស ( ១៩៤៨)**<br>-ដំណោះស្រាយដែលមានប្រសិទ្ធិភាព និងយុត្តិធម៌ ព្រមទាំងសវនាការ ជាសាធារណៈ ។ ( មាត្រា៨ -មាត្រា១0)<br>**កតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ ។ ( មាត្រា ១៤-១)<br>**គោលការណ៍ជាមូលដ្ឋាន ស្តីពីឯករាជ្យភាពក្នុងប្រព័ន្ធ តុលាការ ឆ្នាំ ១៩៨៥**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និង បុគ្គល ។ នីតិវិធីត្រូវតែដំណើរការដោយយុត្តិធម៌ ។ ចៅ ក្រមត្រូវមានសេរីភាព ក្នុងការបង្កើតសមាគម ។ អាណត្តិ របស់ចៅក្រមត្រូវតែធានាដោយច្បាប់គ្រប់គ្រាន់ ។ ( កឋាខ័ណ្ឌទី ៣-៦-៩- |

| | | | | |
|---|---|---|---|---|
| | ដោយសមត្ថភាព និងប្រសិទ្ធិភាព | | -តុលាការមានសមត្ថភាពដែលអាចធានាថា សេចក្តីសម្រេច ត្រូវបានតាមដាន ដោយត្រឹមត្រូវ ( ក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ៦ : ការអនុវត្តដោយបង្ខំ , គន្ថីទី ៣ ជំពូកទី ២ : បណ្តឹងឧទ្ធរណ៍ , គន្ថីទី ៥ ជំពូកទោល : នីតិវិធីដាស់តឿន)<br>-តុលាការត្រូវរៀបចំឡើង ដើម្បីធានាសេចក្តីសម្រេច ត្រូវបានធ្វើឡើងយ៉ាង លឿន និងការបិទ ដោយត្រឹមត្រូវ ( ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៥៨, ៣៧៦, ៣៨១ និងមាត្រា ៣៨២ , ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦៤ , គន្ថីទី ៣ ជំពូកទី ១ ( បទបញ្ញត្តិទូទៅ) និងជំពូកទី ២ ( បណ្តឹងឧទ្ធរណ៍) , មាត្រា ៣៧៦, ៣៨១, ៣៨២ និងមាត្រា ៣៨៦ )<br>-ចៅក្រមបំពេញភារកិច្ចតុលាការ និងរដ្ឋបាល ។ ចៅក្រម ត្រូវត្រួតពិនិត្យ និង ណែនាំ ការងាររបស់បុគ្គលិកតុលាការ ឬបុគ្គលិកអយ្យការ ដោយវិរិយភាព ( ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣២)<br>-តុលាការមានប្រព័ន្ធ និងការរៀបចំ ដើម្បីធានានូវការ ប្រើប្រាស់ ឱ្យមានប្រសិទ្ធភាព ដោយចៅក្រម និង ព្រះរាជអាជ្ញា ( ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣១ និងមាត្រា ៣៣) | ១១)<br>**គោលការណ៍ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា ( ១៩៩០)**<br>-ភាពមិនលំអៀងនៃការជ្រើសរើសព្រះរាជអាជ្ញា និង ការ បណ្តុះបណ្តាលព្រះរាជអាជ្ញាដែលត្រឹមត្រូវ ។ ព្រះរាជ អាជ្ញា ត្រូវបំពេញតួនាទីដោយវិជ្ជាជីវៈ និងផ្តល់សេវា សមហេតុ សមផល ។ ស្ថាប័នអយ្យការត្រូវតែដាច់ដោយ ឡែកពី តុលាការ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញ តួនាទីយ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែល ច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីដោយ ត្រឹមត្រូវ និងការពារការគោរព សិទ្ធិមនុស្ស យកចិត្តទុកដាក់លើ បទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និង បដិសេធនូវរាល់ ភស្តុតាងដែលខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ២-៣-៦-១០-១៦)<br>**គោលការណ៍បឹងហ្គាឡូ ស្តីពីក្រមសីលធម៌របស់ចៅក្រម ( ២០០២)**<br>-ការបំពេញមុខងារនៅក្នុងស្ថាប័នតុលាការ ត្រូវតែមាន សមត្ថភាព និងវិរិយភាព ។ ( តម្លៃទី ៦) |
| | - | **ស្តង់ដារទី ៦ :** តុលាការ ឯករាជ្យ | **រដ្ឋធម្មនុញ្ញ**<br>តុលាការឯករាជ្យ (  មាត្រា ១២៨-ថ្មី) | **សេចក្តីថ្លែងការជាសកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ ដោយ តុលាការ |

| | | | | |
|---|---|---|---|---|
| | | | | ឯករាជ្យ ( មាត្រា ១០)<br>**គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលា ការ (១៩៨៥)**<br>-ឯករាជ្យភាពរបស់តុលាការត្រូវបានធានា មិនត្រូវបាន មានការជ្រៀតជ្រែក ការប្រើប្រាស់នូវនីតិវិធីច្បាប់ ត្រូវ បានផ្តល់ឱ្យនូវធនធានគ្រប់គ្រាន់ ការជ្រើសរើស និង ការបណ្តុះបណ្តាលដោយត្រឹមត្រូវ ធានានូវអាណត្តិរបស់ ចៅក្រម ការតំឡើងឋានៈដោយមិនលំអៀង ការចាត់ ចែងរឿងក្តីផ្ទៃក្នុង និងតុលាការត្រូវប្រកាន់ភ្ជាប់នូវ គោលការណ៍សំងាត់វិជ្ជាជីវៈ ។ ( កឋាខ័ណ្ឌទី ១-៤-៥- ៧-៨-១០-១២-១៥)<br>**គោលការណ៍ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា (១៩៩០)**<br>-ព្រះរាជអាជ្ញាត្រូវបានការពារ នៅពេលត្រូវបានគំរាម កំហែងក្នុងពេលបំពេញការងារ មានសិទ្ធិចូលរួមក្នុង សមាគម ។ ស្ថាប័នអយ្យការត្រូវតែដាច់ដោយ ឡែកពីតុលាការ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែល ច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារការគោរព សិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ភស្តុតាងដែលខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ៤-៥-៦-៩-១០-១៦) |
| **ព្រហ្មទណ្ឌ** | - | **ស្តង់ដាទី 3 :** ត្រូវបានយកទៅដាក់ជូនចៅក្រមភ្លាមៗ | **ក្រមនីតិវិធីព្រហ្មទណ្ឌ** | **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)** |

| | | | | |
|---|---|---|---|---|
| | | | - បុគ្គលដែលត្រូវបានឃាត់ខ្លួន ត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញាភ្លាម ឬដោះលែងឱ្យ មានសេរីភាព ហើយអាចស្នើសុំឱ្យមានមេធាវី ( មាត្រា ៩៨, មាត្រា ១០៣ និងមាត្រា ១០៤) | -ជនត្រូវចោទ ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់ ភ្លាម និងត្រូវបានជំនុំជំរះ ដោយគ្មានការពន្យាពេល ត្រឹមត្រូវ ។ ( មាត្រា ១៤-៣-ក និងមាត្រា ១៤-៣-គ)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ( ១៩៨៩)**<br>-ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់ភ្លាម និងដោយ ផ្ទាល់ និងផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ គឺជាមូលដ្ឋាននៃបញ្ហាក្នុងការសម្រេច ដោយគ្មានការ ពន្យាពេល ។ ( មាត្រា ៤០-២-ខ-ii និងមាត្រា ៤០-២-ខ- iii) |
| | | **ស្តង់ដាទី5 :** តុលាការមាន សមត្ថកិច្ច | **ក្រមនីតិវិធីព្រហ្មទណ្ឌ**<br>-**បណ្តឹងអាជ្ញា អនុវត្តលើបុគ្គលគ្រប់រូប** ទាំងរូបវន្តបុគ្គល និង នីតិបុគ្គល ដោយឥត ប្រកាន់ពូជសាសន៍ ពណ៌ សំបុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើម កំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ( មាត្រា ៣)<br>-**បុគ្គលគ្រប់រូប អាចប្រកាសថាខ្លួនជាជនរងគ្រោះ នៃបទល្មើស និងអាចដាក់ពាក្យ បណ្តឹងបាន** ។ ក្នុងករណីពាក្យបណ្តឹងចិតនៅដោយគ្មានចំឡើយ ឬត្រូវបានតំកល់ទុក ដោយឥត ចាត់ការ ដោយព្រះរាជអាជ្ញា ជនរងគ្រោះ អាចប្តឹងទៅអគ្គព្រះរាជ អាជ្ញាអមសាលាឧទ្ធរណ៍ ( មាត្រា ៦)<br>-**សមត្ថកិច្ចដែនដីរបស់ព្រះរាជអាជ្ញា** គឺទៅតាមទីកន្លែងដែលមានការប្រព្រឹត្ត បទល្មើស , ទីលំនៅរបស់ជនសង្ស័យដែលថាបានប្រព្រឹត្តបទល្មើស , និងទីកន្លែង ចាប់ខ្លួនជនដែលត្រូវបានសង្ស័យ បានប្រព្រឹត្តបទល្មើស ។ ( មាត្រា ៣៩) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-សិទ្ធិទទួលបាននូវដំណោះស្រាយដែលមានប្រសិទ្ធ ភាព ( មាត្រា ៨)<br>**គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលា ការ ( ១៩៨៥)**<br>-តុលាការមានយុត្តាធិការលើអង្គសេចក្តី និងបុគ្គល ។ យុត្តាធិការត្រូវកំណត់ដោយច្បាប់ ។ ចៅក្រម ព្រះរាជ អាជ្ញា និងមេធាវី ត្រូវមានជំនាញ និងចំណេះដឹង ។ ( កឋាខ័ណ្ឌទី ៣) |

| | | | | |
|---|---|---|---|---|
| | | | **-ទំនាក់ទំនងសមត្ថកិច្ចតុលាការព្រហ្មទណ្ឌ និងតុលាការរដ្ឋប្បវេណី :** បណ្ដឹងរដ្ឋប្ប វេណី អាចធ្វើឡើងក្នុងពេលជាមួយ គ្នានឹងបណ្ដឹងអាជ្ញា នៅចំពោះមុខសាលាជំរះក្ដីព្រហ្មទណ្ឌ។ បណ្ដឹងរដ្ឋប្បវេណី ក៏អាចធ្វើផងដែរ នៅចំពោះមុខសាលាជំរះក្ដី រដ្ឋប្បវេណី ។ ក្នុងករណីនេះ បណ្ដឹងរដ្ឋប្បវេណី អាចត្រូវព្យួរសិន ដរាបណាមិនទាន់ មានសេចក្ដីសម្រេចជាស្ថាពរមួយ ត្រូវបានប្រកាស លើបណ្ដឹងអាជ្ញា។ ( មាត្រា ២២)<br>**-របៀបប្ដឹងទៅតុលាការ :** ក្នុងរឿងព្រហ្មទណ្ឌ សាលាដំបូងត្រូវបានទទួលបណ្ដឹង ដោយ (១) ដីកាបញ្ជូនរបស់ ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ, (២) ដីកាបញ្ជូនទៅតុលាការជំនុំជំរះដោយផ្ទាល់របស់ ព្រះរាជអាជ្ញា , និង(៣) កំណត់ ហេតុស្ដីពីការចូល បង្ហាញខ្លួនភ្លាមដោយធ្វើដោយព្រះរាជអាជ្ញា។ ( មាត្រា ២៩១-១) | |
| | | **ស្តង់ដារទី ៨ :** ការយកចិត្តទុកដាក់ចំពោះភាគីដោយស្មើភាពគ្នា | **ក្រមនីតិវិធីព្រហ្មទណ្ឌ :**<br>**-បណ្ដឹងអាជ្ញា អនុវត្តលើបុគ្គលគ្រប់រូប** ទាំងរូបវន្តបុគ្គល និងនីតិបុគ្គល ដោយឥត ប្រកាន់ពូជសាសន៍ ពណ៌ សំបុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើម កំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ( មាត្រា ៣) | **សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និង ត្រូវបាន ការពារដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដោយ គ្មានការរើសអើង។ ( មាត្រា ២-១-២ , មាត្រា ៧ និង មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង |

| | | | | |
|---|---|---|---|---|
| | | | | គ្មានការរើសអើង។ ផលប្រយោជន៍ពិសេសរបស់យុវវ័យត្រូវបានការពារ។ ( មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ( ១៩៦៦)**<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើម កំណើត ជាតិសាសន៍។ ( មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ( ១៩៨៩)**<br>-ការធានានូវសិទ្ធិរបស់កុមារ និងសិទ្ធិរបស់កុមារដែល ត្រូវបានចោទប្រកាន់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ រួម ទាំងសិទ្ធិមានអ្នកបកប្រែ។ ( មាត្រា ២-១ , មាត្រា ៤០-២-ខ-vi)<br>**អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការ រើសអើងប្រឆាំងនឹងស្ត្រីភេទ ( ១៩៧៩)**<br>-ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំង អស់នៃនីតិវិធីក្នុងតុលាការ និងវិធានការសមរម្យ ដើម្បី លុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ ( មាត្រា ១៥-១ , មាត្រា ១៥-២ និងមាត្រា ១៦-១)<br>**គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា- ក្នុងនីតិវិធីព្រហ្មទណ្ឌ ( ១៩៩០)**<br>-ព្រះរាជអាជ្ញាត្រូវអនុវត្តតួនាទីរបស់ខ្លួន ដោយមិន លំអៀង និងចៀសវាងនូវការរើសអើងគ្រប់ប្រភេទ។ ( កឋាខ័ណ្ឌទី ១៣-ក) |

| | | | | |
|---|---|---|---|---|
| | | **ស្តង់ដាទី11:** តុលាការត្រូវ ធានាដល់សាធារណៈជន នូវតម្លាភាព និងការអាច ប្រើប្រាស់បាន | **ក្រមនីតិវិធីព្រហ្មទណ្ឌ :**<br>-ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យបណ្តឹង ដោយតាំងខ្លួនជាដើម បណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ។ ( មាត្រា ៥)<br>**-បុគ្គលគ្រប់រូប អាចប្រកាសថាខ្លួនជាជនរងគ្រោះ នៃបទល្មើស និងអាចដាក់ពាក្យ បណ្តឹងបាន** ។ ក្នុងករណីពាក្យបណ្តឹងឋិតនៅដោយគ្មានចំឡើយ ឬត្រូវបានតំកល់ទុក ដោយឥតចាត់ការ ដោយព្រះរាជអាជ្ញា ជនរងគ្រោះ អាចប្តឹង ទៅអគ្គព្រះរាជ អាជ្ញាអមសាលាឧទ្ធរណ៍ ។ ( មាត្រា ៦ )<br>**-កំណត់ហេតុរបស់នគរបាលយុត្តិធមិ :** នៅពេលធ្វើកំណត់ហេតុ មន្ត្រីនគរបាលអាច ស្នើសុំរកអ្នកបកប្រែភាសាម្នាក់ ។ នៅលើទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធមិ និងដោយអ្នកប្តឹង ។ ( មាត្រា ៧២) | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធមិ និងជាសាធារណៈ ។ ( មាត្រា ១០)<br><br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និងសិទ្ធិនយោ បាយ ( ១៩៦៦)**<br>-ភាពស្មើគ្នានៅក្នុងតុលាការ រួមទាំងសិទ្ធិស្មើគ្នានៅក្នុងតុលាការ និងសិទ្ធិទទួលបានព័តិមាននៅក្នុងភាសាដែលអាចធ្វើបាន ។ ( មាត្រា ១៤-៣-ក) |
| រដ្ឋប្បវេណី | | **ស្តង់ដាទី5 :** តុលាការមាន សមត្ថកិច្ច | **ក្រមនីតិវិធីរដ្ឋប្បវេណី :**<br>-ការចាត់ចែងបណ្តឹងខុសសមត្ថកិច្ចសាលាជំរះក្តី ( មាត្រា ១៨) : តុលាការត្រូវមាន សមត្ថភាពផ្តល់ព័តិមានឱ្យភាគីដាក់ពាក្យបណ្តឹងឱ្យបានត្រឹមត្រូវ តាមសមត្ថកិច្ច ។<br>-ការផ្ទេរដើម្បីចៀសវាងការយឺតយ៉ាវក្នុងករណីខុសសមត្ថកិច្ច ( មាត្រា ១៩) : តុលា ការត្រូវមានប្រព័ន្ធ ដើម្បីជួយសម្រួលក្នុងការផ្ទេរសមត្ថកិច្ច ។<br>**-ដីកាសម្រេចរក្សាការពារ :** រឿងក្តីនៃដីកាសម្រេចរក្សា | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស ( ១៩៤៨)**<br>-ដំណោះស្រាយដែលមានប្រសិទ្ធភាព ( មាត្រា ៨)<br><br>**កតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ( ១៩៦៦)**<br>-សិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងទទួលបានការពារ ដោយច្បាប់ ដោយស្មើភាពគ្នា និងគ្មានការរើសអើង ផលប្រយោជន៏ពិសេសចំពោះយុវវ័យត្រូវបានការពារ និងសិទ្ធិទទួល បាននូវ |

| | | | | |
|---|---|---|---|---|
| | | | ការពារ ត្រូវថិតនៅក្រោម សមត្ថកិច្ចរបស់តុលាការ ដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬសាលាដំបូង ដែលមាន សមត្ថកិច្ចលើទីកន្លែង ដែលវត្ថុ ដែលនឹងត្រូវបានរឹបអូសជា បណ្តោះអាសន្ន ឬវត្ថុដែល ជាកម្មវត្ថុនៃវិវាទដែលថិតនៅ ។ ( មាត្រា ៥៤០)<br>**-ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន :** ពាក្យសុំឱ្យចេញ ដីកាសម្រេចដាស់តឿន ចំពោះកូនបំណុល ត្រូវធ្វើនៅ សាលាដំបូង ដែលមានសមត្ថកិច្ចលើតំបន់ដែលបុគ្គល ថិតនៅ ។ ( មាត្រា ៣២០) | អ្នកបកប្រែដោយឥតគិតថ្លៃ ។ ( មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**គោលការណ៍ជាមូលដ្ឋាន ស្តីពីឯករាជ្យភាពក្នុងប្រព័ន្ធ តុលាការ (១៩៨៥)**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និង បុគ្គល ។ យុត្តាធិការ ត្រូវបានកំណត់ដោយច្បាប់ ។ ចៅក្រមត្រូវ តែមានជំនាញ និងមានចំណេះដឹង ។ ( កឋាខ័ណ្ឌទី ៣ ) |
| | | **ស្តង់ដាទី៩ :** ត្រូវបានគេ យកចិត្តទុកដាក់ដោយ ស្មើភាព | **រដ្ឋធម្មនុញ្ញ :**<br>-សិទ្ធិរបស់បុគ្គលត្រូវបានការពារ ដោយស្មើភាពគ្នាចំពោះ មុខច្បាប់ ( មាត្រា ៣១)<br><br>**ក្រមនីតិវិធីរដ្ឋប្បវេណី :**<br>-ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការ ចំពោះ វិវាទរដ្ឋប្បវេណី ( មាត្រា២)<br>-សិទ្ធិទទួលបាននូវអ្នកបកប្រែ ។ នៅក្នុងតុលាការត្រូវ ប្រើ ភាសាខ្មែរ ( មាត្រា ៥)<br>-ការលុបចោលនូវប្រាតិភោគ ដោយតុលាការ ដោយមូល ហេតុនៃការរលត់នៃប្រាតិ ភោគ ( មាត្រា ៧៣) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និង ត្រូវ បាន ការពារដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដោយ គ្មាន ការរើសអើង ។ ( មាត្រា ២-១-២ , មាត្រា ៧ និង មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវ បានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើស អើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ ។ ( មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (១៩៦៦)**<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើម |

| | | | | |
|---|---|---|---|---|
| | | | | កំណើតជាតិសាសន៍។ (មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)**<br>-ការធានានូវសិទ្ធិរបស់កុមារ និងសិទ្ធិរបស់កុមារដែល ត្រូវបានចោទប្រកាន់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ រួម ទាំងសិទ្ធិមាន អ្នកបកប្រែ។ (មាត្រា ២-១ , មាត្រា ៤០-២-ខ-vi)<br>**អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការ រើសអើងប្រឆាំងនឹងស្ត្រីភេទ (១៩៧៩)**<br>-ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំង អស់នៃនីតិវិធីក្នុងតុលាការ និងវិធានការសមរម្យ ដើម្បី លុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ (មាត្រា ១៥-១ , មាត្រា ១៥-២ និងមាត្រា ១៦-១) |
| | | **ស្តង់ដាទី11 :** តុលាការត្រូវធានាដល់សាធារណៈជននូវ តម្លាភាព និងការអាចប្រើ ប្រាស់បាន | **ក្រមនីតិវិធីរដ្ឋប្បវេណី :**<br>-សិទ្ធិទទួលបាននូវការដោះស្រាយវិវាទរដ្ឋប្បវេណី តាមផ្លូវតុលាការ ត្រូវបានធានា (មាត្រា ២)<br>-សិទ្ធិទាមទារឱ្យសាកសួរ នៅចំពោះមុខ : តុលាការត្រូវគោរព គោលការណ៍ ចំពោះមុខ។ (មាត្រា ៣)<br>-តុលាការត្រូវទទួលខុសត្រូវក្នុងការអនុវត្តបណ្តឹងរដ្ឋប្បវេណី ឱ្យមានភាពយុត្តិធម៌ និងឆាប់រហ័ស។ (មាត្រា ៤)<br>-សិទ្ធិទទួលបានអ្នកបកប្រែ (មាត្រា ៥) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ (មាត្រា ១០) |
| រដ្ឋបាល | | | ត្រូវពន្យល់ឱ្យបានពិស្តារ នៅពេលមានច្បាប់ពិសេស | |
| ពាណិជ្ជកម្ម | | | ត្រូវពន្យល់ឱ្យបានពិស្តារ នៅពេលមានច្បាប់ពិសេស | |
| សង្គម | | | ត្រូវពន្យល់ឱ្យបានពិស្តារ នៅពេលមានច្បាប់ពិសេស | |

## ដំណាក់កាលនៃដំណើររឿងក្តី

### ដំណាក់កាលទី២៖ ការចុះបញ្ជីពាក្យបណ្តឹង/ការទាមទារ

| ប្រភេទរឿងក្តី | ទិសដៅ | ស្តង់ដា | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់ និងបទបញ្ញត្តិជាតិ | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់ និងបទបញ្ញត្តិអន្តរជាតិ |
|---|---|---|---|---|
| ទូទៅ | - តុលាការមានដំណើរការប្រកបដោយតម្លាភាព<br>- មន្ត្រីតុលាការត្រូវមានជំនាញវិជ្ជាជីវៈ និងមានការយល់ដឹងគ្រប់គ្រាន់<br>- តុលាការមានដំណើរការប្រកបដោយសមត្ថភាព និងប្រសិទ្ធិភាព | **ស្តង់ដាទី5 :** តុលាការមានសមត្ថកិច្ច | -តុលាការមានបុគ្គលិកដែលមានសមត្ថភាព អាចវាយតម្លៃលើពាក្យបណ្តឹងរបស់ ប្រជាពលរដ្ឋ ថាតើពាក្យបណ្តឹងនោះ ត្រូវនឹងយុត្តាធិការរបស់តុលាការ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧-២២)<br>-តុលាការត្រូវបានរៀបចំឡើង ដើម្បីឱ្យពាក្យបណ្តឹងរបស់ ប្រជាពលរដ្ឋ អាចចុះ បញ្ជី និងអាចតាមដានបាន (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥0 និង មាត្រា ៧៥ , និងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦)<br>-តុលាការមានបុគ្គលិកដែលមានសមត្ថភាព អាចចាត់ចែងរឿងក្តីដើម្បីកំណត់ បញ្ហាឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៤៧-៣៦៤ និងក្រមនីតិវិធីរដ្ឋប្បវេណី គន្ថី ទី ២ ជំពូកទី ៥ : ការសម្រេចសេចក្តី)<br>-តុលាការមានសមត្ថភាពដែលអាចធានាថា សេចក្តីសម្រេចត្រូវបានតាមដាន ដោយត្រឹមត្រូវ (ក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ៦ | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធមនុស្ស (១៩៤៨)**<br>-ដំណោះស្រាយដែលមានប្រសិទ្ធិភាព និងយុត្តិធម៌ ព្រមទាំងសវនាការ ជាសាធារណៈ ។ (មាត្រា៨ -មាត្រា១០)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ ។ (មាត្រា ១៤-១)<br>**គោលការណ៍ជាមូលដ្ឋាន ស្តីពីឯករាជ្យភាពក្នុងប្រព័ន្ធ តុលាការ ឆ្នាំ ១៩៨៥**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និង បុគ្គល ។ នីតិវិធីត្រូវតែដំណើរការដោយយុត្តិធម៌ ។ ចៅ ក្រមត្រូវមានសេរីភាព ក្នុងការបង្កើតសមាគម ។ អាណត្តិ របស់ចៅក្រម |

| | | | | |
|---|---|---|---|---|
| | | | : ការអនុវត្តដោយបង្ខំ , គន្ថីទី ៣ ជំពូកទី ២ : បណ្តឹងឧទ្ធរណ៍ , គន្ថីទី ៥ ជំពូកទោល : នីតិវិធីដាស់តឿន)<br>-តុលាការត្រូវរៀបចំឡើង ដើម្បីធានាសេចក្តីសម្រេច ត្រូវបានធ្វើឡើងយ៉ាង លឿន និងការបិទ ដោយត្រឹមត្រូវ ( ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៩៨, ៣៧៦, ៣៨១ និងមាត្រា ៣៨២ , ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦៤ , គន្ថីទី ៣ ជំពូកទី ១ (បទបញ្ញត្តិទូទៅ) និងជំពូកទី ២ ( បណ្តឹងឧទ្ធរណ៍) , មាត្រា ៣៧៦, ៣៨១, ៣៨២ និងមាត្រា ៣៨៦ )<br>-ចៅក្រមបំពេញភារកិច្ចតុលាការ និងរដ្ឋបាល ។ ចៅក្រម ត្រូវត្រួតពិនិត្យ និង ណែនាំ ការងាររបស់បុគ្គលិកតុលាការ ឬបុគ្គលិកអយ្យការ ដោយវិរិយភាព ( ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣២)<br>-តុលាការមានប្រព័ន្ធ និងការរៀបចំ ដើម្បីធានានូវការប្រើប្រាស់ឱ្យមានប្រសិទ្ធភាព ដោយចៅក្រម និងព្រះរាជអាជ្ញា ( ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣១ និងមាត្រា ៣៣) | ត្រូវតែធានាដោយច្បាប់គ្រប់គ្រាន់ ។ ( កឋាខ័ណ្ឌទី ៣-៦-៩-១១)<br>**គោលការណ៍ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា ( ១៩៩០)**<br>-ភាពមិនលំអៀងនៃការជ្រើសរើសព្រះរាជអាជ្ញា និង ការបណ្តុះបណ្តាលព្រះរាជអាជ្ញាដែលត្រឹមត្រូវ ។ ព្រះរាជ អាជ្ញាត្រូវបំពេញតួនាទីដោយវិជ្ជាជីវៈ និងផ្តល់សេវា សមហេតុសមផល ។ ស្ថាប័នអយ្យការត្រូវតែដាច់ដោយ ឡែកពីតុលាការ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែល ច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារការគោរពសិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ ភស្តុតាងដែល ខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ២-៣-៦-១០-១៦)<br>**គោលការណ៍បឹងហ្គាឡូ ស្តីពីក្រមសីលធម៌របស់ចៅក្រម (២00២)**<br>-ការបំពេញមុខងារនៅក្នុងស្ថាប័នតុលាការ ត្រូវតែមាន សមត្ថភាព និងវិរិយភាព ។ ( តម្លៃទី ៦) |
| | - | **ស្តង់ដារទី ៨ :** ការយកចិត្តទុកដាក់ចំពោះភាតីដោយស្មើភាពគ្នា | **រដ្ឋធម្មនុញ្ញ :**<br>-សិទ្ធិរបស់បុគ្គលត្រូវបានការពារដោយស្មើភាពគ្នាចំពោះមុខ ច្បាប់ ( មាត្រា ៣១) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និង ត្រូវបានការពារដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដោយ គ្មានការរើសអើង ។ ( មាត្រា ២-១-២ , មាត្រា ៧ និង មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ** |

| | | | | |
|---|---|---|---|---|
| | | | | (១៩៦៦)<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការ ពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ។ (មាត្រា ១៤-១, មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (១៩៦៦)**<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើម កំណើតជាតិសាសន៍។ (មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)**<br>-ការធានានូវសិទ្ធិរបស់កុមារ និងសិទ្ធិរបស់កុមារដែលត្រូវបានចោទ ប្រកាន់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ រួម ទាំងសិទ្ធិមានអ្នកបកប្រែ។ (មាត្រា ២-១, មាត្រា ៤០-២-ខ-vi)<br>**អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការ រើសអើងប្រឆាំងនឹងស្ត្រីភេទ (១៩៧៩)**<br>-ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំង អស់នៃនីតិវិធី ក្នុងតុលាការ និងវិធានការសមរម្យ ដើម្បី លុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ (មាត្រា ១៥-១, មាត្រា ១៥-២ និងមាត្រា ១៦-១)<br>**គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា- ក្នុងនីតិវិធីព្រហ្មទណ្ឌ (១៩៩០)**<br>-ព្រះរាជអាជ្ញាត្រូវអនុវត្តតួនាទីរបស់ខ្លួន ដោយមិន លំអៀង និង |

| | | | | |
|---|---|---|---|---|
| | | | | ចៀសវាងនូវការរើសអើងគ្រប់ប្រភេទ។ (កឋាខ័ណ្ឌទី ១៣-ក) |
| | | **ស្តង់ដាទី11:** តុលាការត្រូវធានាដល់សាធារណៈជននូវតម្លាភាព និងការអាចប្រើប្រាស់បាន | **គោលការណ៍នៃភាពសុចរិត :** បុគ្គលសុចរិត គឺជាបុគ្គលដែលទៀងត្រង់ និងមិនប្រព្រឹត្តអំពើពុករលួយ ។ (មាត្រា ១៨) | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស (១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ។ (មាត្រា ១០)<br><br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>-ភាពស្មើគ្នានៅក្នុងតុលាការ រួមទាំងសិទ្ធិស្មើគ្នានៅក្នុង តុលាការ និងសិទ្ធិទទួលបានព័ត៌មាននៅក្នុងភាសាដែល អាចធ្វើបាន។ (មាត្រា ១៤-៣-ក) |
| ព្រហ្មទណ្ឌ | | **ស្តង់ដាទី5 :** តុលាការមានសមត្ថកិច្ច | **ក្រមនីតិវិធីព្រហ្មទណ្ឌ:**<br>**-បញ្ជីនៃពាក្យបណ្តឹង :** នៅតាមតុលាការជាន់ដំបូងនីមួយៗ ត្រូវបង្កើតឱ្យមានបញ្ជី អយ្យការមួយ សម្រាប់ចុះបណ្តឹងដែលប្តឹងដោយ ផ្ទាល់ដល់ព្រះ រាជអាជ្ញា ឬបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌។ (មាត្រា ៥០)<br>**-បញ្ជីបណ្តឹង :** នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវមានបញ្ជីបណ្តឹងមួយ នៅគ្រប់ពេលដែលមានការដាក់បណ្តឹង មន្ត្រីនគរបាល ត្រូវចុះបញ្ជីនូវនិទ្ទេសដូចមានចែងក្នុងមាត្រានេះ។ (មាត្រា ៧៣) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)**<br>-សិទ្ធិទទួលបាននូវដំណោះស្រាយដែលមានប្រសិទ្ធ ភាព (មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិ ពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង។ (មាត្រា ១៤-១ និងមាត្រា ២៦)<br>**គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលាការ (១៩៨៥)**<br>-តុលាការមានយុត្តាធិការលើអង្គសេចក្តី និងបុគ្គល។ (កឋាខ័ណ្ឌទី ៣) |
| | | **ស្តង់ដាទី៩:** ត្រូវបាន | **ក្រមនីតិវិធីព្រហ្មទណ្ឌ:** | |

| | | | | |
|---|---|---|---|---|
| | | គេយកចិត្តទុកដាក់ដោយស្មើភាព | **-បញ្ជីនៃពាក្យបណ្តឹង :** នៅតាមតុលាការជាន់ដំបូងនីមួយៗ ត្រូវបង្កើតឱ្យមានបញ្ជី អយ្យការមួយ សម្រាប់ចុះបណ្តឹងដែល ប្តឹងដោយ ផ្ទាល់ដល់ព្រះរាជអាជ្ញា ឬបញ្ជូនមកដោយមន្ត្រី នគរបាលយុត្តិធម៌ ។ ( មាត្រា ៥០)<br>**-បញ្ជីបណ្តឹង :** នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវមានបញ្ជីបណ្តឹងមួយ នៅគ្រប់ពេលដែលមានការដាក់បណ្តឹង មន្ត្រីនគរបាល ត្រូវចុះបញ្ជីនូវនិទ្ទេសដូចមានចែងក្នុងមាត្រានេះ ។ ( មាត្រា ៧៣) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និង ត្រូវបានការពារដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដោយ គ្មានការរើសអើង ។ ( មាត្រា ២-១-២ , មាត្រា ៧ និង មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ ។ ( មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (១៩៦៦)**<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើម កំណើតជាតិសាសន៍ ។ ( មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ( ១៩៨៩)**<br>-ការធានានូវសិទ្ធិរបស់កុមារ និងសិទ្ធិរបស់កុមារដែល ត្រូវបានចោទ ប្រកាន់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ រួម ទាំងសិទ្ធិមានអ្នកបកប្រែ ។ ( មាត្រា ២-១ , មាត្រា ៤០-២-ខ-vi)<br>**អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការ រើសអើងប្រឆាំងនឹងស្ត្រីភេទ ( ១៩៧៩)**<br>-ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំង អស់នៃនីតិវិធីក្នុងតុលាការ និងវិធានការសមរម្យ ដើម្បី លុបបំបាត់ការរើស |

| | | | | |
|---|---|---|---|---|
| | | | | អើងប្រឆាំងនឹងស្ត្រីភេទ។ ( មាត្រា ១៥-១ , មាត្រា ១៥-២ និងមាត្រា ១៦-១)<br>**គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា- ក្នុងនីតិវិធីព្រហ្មទណ្ឌ ( ១៩៩០)**<br>-ព្រះរាជអាជ្ញាត្រូវអនុវត្តតួនាទីរបស់ខ្លួន ដោយមិន លំអៀង និងចៀសវាងនូវការរើសអើងគ្រប់ប្រភេទ។ ( កឋាខ័ណ្ឌទី ១៣-ក) |
| | | **ស្តង់ដាទី11 :** តុលាការត្រូវធានាដល់សាធារណៈជននូវ តម្លាភាព និងការអាចប្រើប្រាស់បាន | **ក្រមនីតិវិធីព្រហ្មទណ្ឌ :**<br>-**ការដាក់បណ្តឹងអាជ្ញាឱ្យមានចលនាដោយជនរងគ្រោះ :** ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យបណ្តឹងដោយតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ។ ( មាត្រា ៥)<br>-**ការដាក់ពាក្យប្តឹងទាមទារដោយជនរងគ្រោះ :** បុគ្គលគ្រប់រូបដែលប្រកាសថា ខ្លួនជាអ្នករងគ្រោះនៃបទល្មើសអាចដាក់ពាក្យប្តឹងបាន។ ក្នុងករណីគ្មានចម្លើយ ឬតំកល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ( មាត្រា ៦)<br>-**បញ្ជីនៃពាក្យបណ្តឹង :** នៅតាមតុលាការជាន់ដំបូងនីមួយៗ ត្រូវបង្កើតឱ្យមានបញ្ជី អយ្យការមួយ សម្រាប់ចុះបណ្តឹងដែលប្តឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌។ ( មាត្រា ៥០-១)<br>-**បញ្ជីនៃពាក្យបណ្តឹង** ត្រូវកាន់កាប់ដោយលេខាធិការរបស់ | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ ( មាត្រា ១០)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ( ១៩៦៦)**<br>-ភាពស្មើគ្នានៅចំពោះតុលាការ រួមមានសិទ្ធិស្មើគ្នានៅចំពោះមុខតុលាការ និងសិទ្ធិទទួលបានព័ត៌មាន តាមរយៈភាសា ដែលអាចយល់បានភ្លាម។ ( មាត្រា ១៤-៣-ក) |

| | | | | |
|---|---|---|---|---|
| | | | អយ្យការ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។ បញ្ជីអាចត្រូវបានបើកមើល ដោយអាជ្ញាធរតុលាការទាំងអស់ ជាអាទិ៍ គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ (មាត្រា ៥០-៣)<br>**-កំណត់ហេតុរបស់នគរបាលយុត្តិធម៌ :** គ្រប់បណ្តឹងដែលទទួលបានដោយមន្ត្រីនគរបាលយុត្តិធម៌ តម្រូវឱ្យធ្វើកំណត់ហេតុ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ អាចស្នើឱ្យមានអ្នកបកប្រែបាន។ ទំព័រនីមួយៗនៃកំណត់ហេតុនគរបាលយុត្តិធម៌ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹង។ ការឆូតការថែម និងការយោង ត្រូវមានបញ្ជាក់ដោយហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្តឹងនូវរាល់ទំព័រ។ (មាត្រា ៧២)<br>**-បញ្ជីបណ្តឹង :** នៅគ្រប់អង្គភាពនគរបាលយុត្តិធម៌ ត្រូវមានបញ្ជីបណ្តឹងមួយ នៅគ្រប់ពេលដែលមានការដាក់បណ្តឹង មន្ត្រីនគរបាល ត្រូវចុះបញ្ជីនូវនិទ្ទេសដូចមានចែងក្នុងមាត្រានេះ។ (មាត្រា ៧៣) | |
| **រដ្ឋប្បវេណី** | | **ស្តង់ដាទី ៤ :** ទទួលបាននូវការកាត់សេចក្តីនៅក្នុងរយៈមួយដ៏សមស្រប | **ក្រមនីតិវិធីរដ្ឋប្បវេណី**<br>-ប្រធានតុលាការ ត្រូវបង្កើតឱ្យមានប្រព័ន្ធបែងចែករឿងក្តីប្រចាំឆ្នាំនៅក្នុងតុលាការ។ (មាត្រា ២៦) | **អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)**<br>-ផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ គឺជាមូលដ្ឋាននៃការ សម្រេចបញ្ហា ដោយគ្មានភាពលំអៀង។ (មាត្រា ៤០-២-ខ-ii និងមាត្រា ៤០-២-ខ-iii) |
| | | **ស្តង់ដាទី5 :**<br>តុលាការមាន សមត្ថកិច្ច | **ក្រមនីតិវិធីរដ្ឋប្បវេណី**<br>-ប្រធានតុលាការ ត្រូវបង្កើតឱ្យមានប្រព័ន្ធបែងចែករឿងក្តី ប្រចាំឆ្នាំនៅក្នុងតុលាការ។ (មាត្រា ២៦)<br>-ការដាក់ពាក្យនៃរឿងក្តីដែលមានចំនួនទឹកប្រាក់តិច អាចធ្វើ | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)**<br>-ដំណោះស្រាយដែលមានប្រសិទ្ធភាព (មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)** |

| | | | | |
|---|---|---|---|---|
| | | | ដោយ ផ្ទាល់មាត់ នៅចំពោះក្រឡាបញ្ជី។ ក្រឡាបញ្ជីត្រូវកត់ត្រានូវសេចក្តីថ្លែងការរបស់ដើមចោទក្នុងកំណត់ហេតុ។ ក្នុងករណីនេះ កំណត់ហេតុនោះ ត្រូវចាត់ទុកថា ជាពាក្យបណ្តឹង។ (មាត្រា ២២៥)<br>-ពាក្យសុំឱ្យចេញដីកាសម្រេចដាស់តឿន ត្រូវធ្វើដូចគ្នានឹងបទបញ្ញត្តិស្តីពីបណ្តឹង។ (មាត្រា ៣២១)<br>-តុលាការដែលមានសមត្ថកិច្ចនៅក្នុងរឿងក្តីនៃដីកាសម្រេចរក្សាការពារ ត្រូវឋិតនៅក្រោម សមត្ថកិច្ចរបស់តុលាការ ដែលមានសមត្ថកិច្ចលើអង្គសេចក្តី ឬសាលាដំបូង ដែលមានសមត្ថកិច្ចលើទីកន្លែង ដែលវត្ថុដែលនឹងត្រូវបានរឹបអូសជាបណ្តោះអាសន្ន ឬវត្ថុដែល ជាកម្មវត្ថុនៃវិវាទដែលឋិតនៅ។ (មាត្រា ៥៤០) | -ភាពស្មើគ្នានៅចំពោះមុខច្បាប់ និងទទួលបានការពារ ស្មើភាពគ្នាចំពោះមុខច្បាប់ ដោយគ្មានរើសអើង។ (មាត្រា ១៤-១ និង មាត្រា ២៦)<br>**គោលការណ៍ជាមូលដ្ឋានស្តីពី ឯករាជ្យភាពរបស់តុលាការ (១៩៨៥)**<br>-តុលាការត្រូវមានយុត្តាធិការលើអង្គសេចក្តី និងបុគ្គល។ (កថាខ័ណ្ឌទី ៣) |
| | | **ស្តង់ដាទី៥:** ត្រូវបានគេយកចិត្តទុកដាក់ ដោយស្មើភាព | **ក្រមនីតិវិធីរដ្ឋប្បវេណី**<br>-ជនគ្រប់រូបមានសិទ្ធិទទួលបាននូវការជំនុំជំរះក្នុងរឿងក្តីរដ្ឋប្បវេណី (មាត្រា ២)<br>-សិទ្ធិរបស់ភាគីក្នុងការស្នើសុំអ្នកបកប្រែ ក្នុងករណីមិនចេះភាសាខ្មែរ (មាត្រា ៥)<br>**-ការលុបចោលនូវប្រាតិភោគ :** តុលាការត្រូវចេញដីកាសម្រេចលុបចោលនូវប្រាតិភោគ ប្រសិនបើអ្នកដែលបានដាក់ប្រាតិភោគ បានបញ្ជាក់នូវការរលត់នៃហេតុដែលត្រូវដាក់ប្រាតិភោគ។ (មាត្រា ៧៣-២) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និង ត្រូវបានការពារដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដោយ គ្មានការរើសអើង។ (មាត្រា ២-១-២ , មាត្រា ៧ និង មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ។ (មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌** |

| | | | | |
|---|---|---|---|---|
| | | | | (១៩៦៦)<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើម កំណើតជាតិសាសន៍។ (មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)**<br>-ការធានានូវសិទ្ធិរបស់កុមារ និងសិទ្ធិរបស់កុមារដែល ត្រូវបានចោទប្រកាន់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ រួម ទាំងសិទ្ធិមានអ្នកបកប្រែ។ (មាត្រា ២-១ , មាត្រា ៤០-២-ខ-vi)<br>**អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការ រើសអើងប្រឆាំងនឹងស្ត្រីភេទ (១៩៧៩)**<br>-ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំង អស់នៃនីតិវិធីក្នុងតុលាការ និងវិធានការសមរម្យ ដើម្បី លុបបំបាត់ការ រើសអើង ប្រឆាំងនឹងស្ត្រីភេទ។ (មាត្រា ១៥-១ , មាត្រា ១៥-២ និង មាត្រា ១៦-១)<br>**គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា- ក្នុងនីតិវិធីព្រហ្មទណ្ឌ (១៩៩០)**<br>-ព្រះរាជអាជ្ញាត្រូវអនុវត្តតួនាទីរបស់ខ្លួន ដោយមិនលំអៀង និងចៀសវាងនូវការរើសអើងគ្រប់ប្រភេទ។ (កឋាខ័ណ្ឌទី ១៣-ក) |
| | | **ស្តង់ដាទី11 :**<br>តុលាការត្រូវធានាដល់សាធារណៈជន នូវតម្លាភាព | **ក្រមនីតិវិធីរដ្ឋប្បវេណី**<br>-ជនគ្រប់រូបមានសិទ្ធិទទួលបាននូវការជំនុំជំរះក្នុងរឿងក្តីរដ្ឋប្បវេណី (មាត្រា ២)<br>-សវនាការចំពោះមុខភាគី : តុលាការត្រូវគោរពគោលការណ៍ | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ (មាត្រា១០)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)** |

| | | | | |
|---|---|---|---|---|
| | | និងការអាចប្រើប្រាស់បាន | ចំពោះមុខ។ ( មាត្រា ៣)<br>-តុលាការត្រូវធានាឱ្យបណ្ដឹងរដ្ឋប្បវេណី ប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស។ ( មាត្រា ៤)<br>-សិទ្ធិរបស់ភាគីក្នុងការស្នើសុំអ្នកបកប្រែ ក្នុងករណីមិនចេះភាសាខ្មែរ ( មាត្រា ៥)<br>-ការជូនដំណឹងអំពីបណ្ដឹង : ការជូនដំណឹងអំពីបណ្ដឹង ត្រូវធ្វើឡើងដោយលិខិតបញ្ជាក់ជាលាយលក្ខណ៍អក្សរ ដែលបញ្ជាក់អំពីមូលហេតុក្នុងការជូនដំណឹង និងអំពីដំណើរការនៃបណ្ដឹងនោះទៅតុលាការ។ តុលាការត្រូវបញ្ជូនលិខិតនោះទៅអ្នកដែលត្រូវទទួលដំណឹង និងភាគីម្ខាងទៀតនៃបណ្ដឹង។ ( មាត្រា ៥០-៣)<br>-អត្ថន័យ និងប្រភេទនៃប្រាក់ប្រដាប់ក្ដី : ភាគីតម្រូវឱ្យបង់ប្រាក់ប្រដាប់ក្ដីតុលាការ រួមមានពន្ធដាក់ពាក្យសុំប្រាក់ប្រដាប់ក្ដីតុលាការក្រៅពីពន្ធ និងប្រាក់ប្រដាប់ក្ដីភាគី។ ( មាត្រា ៥៩ ដល់មាត្រា ៦៣)<br>-ដីកាសម្រេចឱ្យដាក់ប្រាតិភោគ : តុលាការបង្គាប់ឱ្យដើមចោទដាក់ប្រាតិភោគលើប្រាក់ប្រដាប់ក្ដី តាមពាក្យសុំរបស់ចុងចម្លើយដោយដីកាសម្រេច ប្រសិនបើដើមចោទគ្មានលំនៅដ្ឋាន ទីស្នាក់ការឬទីកន្លែងអាជីវកម្មនៅព្រះរាជាណាចក្រកម្ពុជា។ ( មាត្រា ៦៧)<br>-ការរឹបអូសទ្រព្យសម្បត្តិ : ការរឹបអូសទ្រព្យអាចធ្វើបានចំពោះរូបទ្រព្យ ឬអរូបទ្រព្យទាំងអស់ ដែលធ្លាក់លើកូនបំណុលនៃការអនុវត្ត។ ( មាត្រា ៣៧៩)<br>**ក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា**<br>-ចៅក្រមបំពេញកិច្ចការតុលាការផង និងកិច្ចការរដ្ឋបាលផង។ | -ភាពស្មើគ្នានៅក្នុងតុលាការ រួមទាំងសិទ្ធិស្មើគ្នានៅក្នុង តុលាការ និងសិទ្ធិទទួលបានព័ត៌មាននៅក្នុងភាសាដែល អាចធ្វើបាន។ ( មាត្រា ១៤-៣-ក) |

| | | | | |
|---|---|---|---|---|
| | | | ចៅក្រមត្រូវត្រួតពិនិត្យការងារដែលបំពេញដោយបុគ្គលិកតុលាការ ឬអយ្យការ -**តុលាការត្រូវធានាថា ការចុះបញ្ជីធ្វើឡើងដោយតម្លាភាព**។ (មាត្រា ៣២) | |
| រដ្ឋបាល | | | ត្រូវពន្យល់ឱ្យបានពិស្តារ នៅពេលមានច្បាប់ពិសេស | |
| ពាណិជ្ជកម្ម | | | ត្រូវពន្យល់ឱ្យបានពិស្តារ នៅពេលមានច្បាប់ពិសេស | |
| សង្គម | | | ត្រូវពន្យល់ឱ្យបានពិស្តារ នៅពេលមានច្បាប់ពិសេស | |

# ដំណាក់កាលនៃដំណើររឿងក្តី

## <u>ដំណាក់កាលទី៣~ ការពិនិត្យការទាមទារ/ការអនុវត្តបណ្តឹងអាជ្ញា(បណ្តឹងអាជ្ញា)</u>

| ប្រភេទរឿងក្តី | ទិសដៅ | ស្តង់ដារ | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់និង បទបញ្ញត្តិជាតិ | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់ និង បទបញ្ញត្តិអន្តរជាតិ |
|---|---|---|---|---|
| ទូទៅ | - តុលាការ មានដំណើរការប្រកប ដោយ តម្លាភាព<br>- ចៅក្រមសម្រេចសេចក្តី ដោយឯករាជ្យ<br>-មន្ត្រីតុលាការ ត្រូវមានជំនាញវិជ្ជាជីវៈ និងមានការយល់ដឹងគ្រប់គ្រាន់<br>- មន្ត្រីតុលាការ បម្រើការងារ ដោយគោរពក្រមសីលធម៌<br>- ដំណើរការតុលាការ ត្រូវបានធ្វើឡើងដោយមិនលំអៀង យុត្តិធម៌ និងប្រកបដោយ វិជ្ជាជីវៈ<br>-តុលាការមានដំណើរការប្រកប ដោយសមត្ថភាព និងប្រសិទ្ធិភាព | **ស្តង់ដារទី5 :** តុលាការមាន សមត្ថកិច្ច | -តុលាការត្រូវបានរៀបចំឡើង ដើម្បីឱ្យពាក្យបណ្តឹង របស់ប្រជាពលរដ្ឋអាចចុះ បញ្ជី និងអាចតាមដានបាន (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥0 និង មាត្រា ៧៥ , និងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦)<br>-តុលាការមានបុគ្គលិកដែលមានសមត្ថភាព អាចចាត់ចែងរឿងក្តី ដើម្បីកំណត់ បញ្ហាឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៤៧-៣៦៤ និងក្រមនីតិវិធីរដ្ឋប្បវេណី គន្ថី ទី ២ ជំពូកទី ៥ : ការសម្រេចសេចក្តី)<br>-តុលាការមានសមត្ថភាពដែលអាចធានាថា សេចក្តីសម្រេចត្រូវបានតាមដាន ដោយត្រឹមត្រូវ (ក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ៦ : ការអនុវត្តដោយបង្ខំ , គន្ថីទី ៣ ជំពូកទី ២ : បណ្តឹងឧទ្ធរណ៍ , គន្ថីទី ៥ ជំពូកទោល : នីតិវិធីដាស់តឿន)<br>-តុលាការត្រូវរៀបចំឡើង ដើម្បីធានាសេចក្តីសម្រេចត្រូវបានធ្វើឡើងយ៉ាង លឿន និងការបិទ ដោយត្រឹមត្រូវ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៥៨, ៣៧៦, ៣៨១ | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធមនុស្ស (១៩៤៨)**<br>-ដំណោះស្រាយដែលមានប្រសិទ្ធិភាព និងយុត្តិធម៌ ព្រមទាំងសវនាការ ជាសាធារណៈ ។ (មាត្រា៨ -មាត្រា១០)<br>**កតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ ។ (មាត្រា ១៤-១)<br>**គោលការណ៍ជាមូលដ្ឋាន ស្តីពីឯករាជ្យភាពក្នុងប្រព័ន្ធតុលាការ ឆ្នាំ ១៩៨៥**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និង បុគ្គល ។ នីតិវិធីត្រូវតែដំណើរការដោយយុត្តិធម៌ ។ ចៅ ក្រមត្រូវមានសេរីភាពក្នុងការបង្កើតសមាគម ។ អាណត្តិ របស់ចៅក្រម ត្រូវតែធានាដោយច្បាប់គ្រប់គ្រាន់ ។ (កឋាខ័ណ្ឌទី ៣- |

| | | | | |
|---|---|---|---|---|
| | | | និងមាត្រា ៣៨២ , ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦៤ , គន្ថីទី ៣ ជំពូកទី ១ ( បទបញ្ញត្តិទូទៅ) និងជំពូកទី ២ ( បណ្តឹងឧទ្ធរណ៍) , មាត្រា ៣៧៦, ៣៨១, ៣៨២ និងមាត្រា ៣៨៦ )<br>-ចៅក្រមបំពេញភារកិច្ចតុលាការ និងរដ្ឋបាល ។ ចៅក្រមត្រូវត្រួតពិនិត្យ និង ណែនាំ ការងាររបស់បុគ្គលិកតុលាការ ឬបុគ្គលិកអយ្យការ ដោយវិរិយភាព ( ក្រមសីលធមិ ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣២)<br>-តុលាការមានប្រព័ន្ធ និងការរៀបចំ ដើម្បីធានានូវការប្រើប្រាស់ ឱ្យមានប្រសិទ្ធភាព ដោយចៅក្រម និង ព្រះរាជអាជ្ញា ( ក្រមសីលធមិ ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣១ និងមាត្រា ៣៣) | ៦-៩-១១)<br>**គោលការណ៍ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា ( ១៩៩០)**<br>-ភាពមិនលំអៀងនៃការជ្រើសរើសព្រះរាជអាជ្ញា និងការបណ្តុះបណ្តាលព្រះរាជអាជ្ញាដែលត្រឹមត្រូវ ។ ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីដោយវិជ្ជាជីវៈ និងផ្តល់សេវាសមហេតុសមផល ។ ស្ថាប័នអយ្យការត្រូវតែដាច់ដោយឡែកពីតុលាការ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែលច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារការគោរពសិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និងបដិសេធនូវវាល់ភស្តុតាងដែលខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ២-៣-៦-១០-១៦)<br>**គោលការណ៍បឹងហ្កាឡូ ស្តីពីក្រមសីលធមិរបស់ចៅក្រម**<br>( ២០០២)<br>-ការបំពេញមុខងារនៅក្នុងស្ថាប័នតុលាការ ត្រូវតែមានសមត្ថភាព និងវិរិយភាព ។ ( តម្លៃទី ៦) |
| | | **ស្តង់ដាទី 6 :** តុលាការ ឯករាជ្យ | **រដ្ឋធម្មនុញ្ញ**<br>តុលាការឯករាជ្យ ( មាត្រា ១២៨-ថ្មី)<br>**ក្រមសីលធមិ ចៅក្រម និងព្រះរាជអាជ្ញា**<br>ចៅក្រមនិងព្រះរាជអាជ្ញាត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធមិ និងជាសាធារណៈដោយតុលាការឯករាជ ។ ( មាត្រា ១០)<br>**គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលា ការ** |

| | | | | |
|---|---|---|---|---|
| | | | ឯករាជភាព។ (ជំពូក២: មាត្រា ២-៦) | **(១៩៨៥)**<br>-ឯករាជ្យភាពរបស់តុលាការត្រូវបានធានា មិនត្រូវបានមានការជ្រៀតជ្រែក ការប្រើប្រាស់នូវនីតិវិធីច្បាប់ ត្រូវបានផ្តល់ឱ្យនូវធនធានគ្រប់គ្រាន់ ការជ្រើសរើស និងការបណ្តុះបណ្តាលដោយត្រឹមត្រូវ ធានានូវអាណត្តិរបស់ចៅក្រម ការតំឡើងឋានៈ ដោយមិនលំអៀង ការចាត់ចែងរឿងក្តីផ្ទៃក្នុង និងតុលាការ ត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍សំងាត់វិជ្ជាជីវៈ។ (កឋាខ័ណ្ឌទី ១-៤-៥- ៧-៨-១០-១២-១៥) |
| | | **ស្តង់ដាទី 7 :** តុលាការមិន លំអៀង | **ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា**<br>ចៅក្រមនិងព្រះរាជអាជ្ញាត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍អនាគតិ។ (ជំពូក៣: មាត្រា ៧-១៥) | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស (១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ។ (មាត្រា ១០)<br>**គោលការណ៍ជាមូលដ្ឋានស្តីពី ឯករាជ្យភាពរបស់តុលាការ (១៩៨៥)**<br>- តុលាការត្រូវសំរេចរឿងរ៉ាវផ្សេងៗដោយមិនលំអៀង ផ្អែកតាមមូលដ្ឋានជាក់ស្តែងនិងច្បាប់។(ឯករាជភាពតុលាការ-ចំណុចលេខ ២) |
| ព្រហ្មទណ្ឌ | | **ស្តង់ដាទី1:** វិធានការចាប់បង្ខំក្នុងនីតិវិធីព្រហ្មទណ្ឌ ត្រូវមានការយល់ព្រមពី តុលាការ | **ក្រមនីតិវិធីព្រហទណ្ឌ:**<br>**-បញ្ជីនៃពាក្យប្តឹង**ត្រូវកាន់កាប់ដោយលេខាធិការរបស់អយ្យការ ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា ។ បញ្ជីអាចត្រូវបានបើកមើលដោយអាជ្ញាធរតុលាការទាំងអស់ជាអាទិ៍ គឺអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។(មាត្រា ៥០-៣) | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស (១៩៤៨)**<br>- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ឬការនិរទេសខ្លួន លុះត្រាណាតែមានច្បាប់អនុញ្ញាត។ (មាត្រា ៩)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)** |

| | | | | |
|---|---|---|---|---|
| | | | - **ការឆែកឆេរ:**<br>មន្ត្រីនគរបាលយុត្តិធមិអាចធ្វើការឆែកឆេរ បាន ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធមិត្រូវទទួល ជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជា ការ អនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។(មាត្រា ៩១)<br>- **ការឃាត់ខ្លួនដោយ** មន្ត្រីនគរបាលយុត្តិធមិត្រូវមានការ យល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជ អាជ្ញា ។(មាត្រា ៩៦) | - ត្រូវបានជូនដំណឹងភ្លាមអំពីការចោទប្រកាន់ និងត្រូវនាំខ្លួន ភ្លាមមកឱ្យចៅក្រម ។ ត្រូវចាត់ទុកថាគ្មានទោស ។ មាន សមត្ថភាពក្នុងការពិនិត្យសាក្សី ។ សេរីភាពរួចផុត ពីការ ធ្វើទារុណកម្ម ។ (មាត្រា ៧ មាត្រា ៩ មាត្រា ១៤-២ មាត្រា ១៤-៣-ង មាត្រា ១៥) |
| | | **ស្តង់ដាទី 3 :** ត្រូវបានយក ទៅដាក់ជូនចៅក្រមភ្លាមៗ | **ក្រមនីតិវិធីព្រហទណ្ឌ:**<br>- **ការបើកការស៊ើបសួរៈក្នុងករណីបទឧក្រិដ្ឋ** ព្រះរាជអាជ្ញា ត្រូវតែបើកការស៊ើបសួរ ។ ការស៊ើបសួរត្រូវបាន បើក តាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្ដឹងទៅចៅក្រម ស៊ើបសួរ ។ (មាត្រា ៤៤)<br>- **ការចោទប្រកាន់ក្នុងករណីបទមជ្ឈិមៈ**ក្នុងករណីបទមជ្ឈិម ព្រះរាជអាជ្ញាអាចបើកការស៊ើបសួរ ។ (មាត្រា ៤៥)<br>- **ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់** គឺជាបញ្ជាឱ្យជន ជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ។ (មាត្រា ៤៦)<br>- **ការបង្ហាញខ្លួនភ្លាមៈ** ព្រះរាជអាជ្ញាអាចបង្គាប់ឱ្យនាំខ្លួន ជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅមុខតុលាការជាន់ដំបូង ។(មាត្រា ៤៧)<br>- **ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ក្នុងករណីបទលហុះ** | **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>-ជនត្រូវចោទ ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់ ភ្លាម និងត្រូវបានជំនុំជំរះ ដោយគ្មានការពន្យាពេល ត្រឹមត្រូវ ។ (មាត្រា ១៤-៣-ក និងមាត្រា ១៤-៣-គ)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)**<br>-ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់ភ្លាម និងដោយ ផ្ទាល់ និងផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ គឺជាមូលដ្ឋាននៃ បញ្ហាក្នុងការសម្រេច ដោយគ្មានការ ពន្យាពេល ។ (មាត្រា ៤០-២-ខ-ii និងមាត្រា ៤០-២-ខ- iii) |

| | | | | |
|---|---|---|---|---|
| | | | ប្រសិនបើរឿងនោះជាបទលហុ ព្រះរាជអាជ្ញាត្រូវកោះជន ជាប់ចោទឱ្យចូលខ្លួនទៅមុខតុលាការជំនុំជម្រះដោយផ្ទា ល់ ។( មាត្រា ៤៩)<br>**ក្រមសីលធមិ ចៅក្រម និងព្រះរាជអាជ្ញា**<br>- ចៅក្រមបំពេញភារកិច្ចតុលាការ និងរដ្ឋបាល ។ ចៅក្រម ត្រូវត្រួតពិនិត្យ និង ណែនាំ ការងាររបស់បុគ្គលិកតុលាការ ឬបុគ្គលិកអយ្យការ ដោយវិរិយភាព ( មាត្រា ៣២)<br>-តុលាការមានប្រព័ន្ធ និងការរៀបចំ ដើម្បីធានានូវការ ប្រើប្រាស់ ឱ្យមានប្រសិទ្ធភាព ដោយចៅក្រម និង ព្រះរាជអាជ្ញា ( មាត្រា ៣១ និងមាត្រា ៣៣) | |
| | - | **ស្តង់ដាទី5 :** តុលាការមាន សមត្ថកិច្ច | **ក្រមនីតិវិធីព្រហ្មទណ្ឌ: ការអនុវត្តបណ្តឹ អាជ្ញា** ( មាត្រា ៤0ដល់ មាត្រា ៥0)<br>-ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និង ពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែល មន្ត្រី នគរបាល យុត្តិធមិបញ្ជូនមក ។<br>- ព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ ។មុននឹងសម្រេច ព្រះរាជអាជ្ញាបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការ ស្រាវជ្រាវបន្ថែម ។<br>- ក្នុងករណីមានបទល្មើសធ្ងន់ធ្ងរព្រះរាជអាជ្ញារាយការណ៍ ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលត្រូវ រាយការណ៍ | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>- -ដំណោះស្រាយដែលមានប្រសិទ្ធិភាព និងយុត្តិធមិ ព្រមទាំងសវនាការ ជាសាធារណៈ ។ ( មាត្រា៨ -មាត្រា១០)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ ( ១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង ។ ( មាត្រា ១៤-១ , និងមាត្រា ២៦)<br>**គោលការណ៍ជាមូលដ្ឋានស្តីពី ឯករាជ្យភាពរបស់តុលាការ ( ១៩៨៥)**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និង បុគ្គល ។ |

| | | | | |
|---|---|---|---|---|
| | | | បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។ | នីតិវិធីត្រូវតែដំណើរការដោយយុត្តិធម៌ ។ ចៅក្រមត្រូវមានសេរីភាពក្នុងការបង្កើតសមាគម ។ អាណត្តិ របស់ចៅក្រមត្រូវតែធានាដោយច្បាប់គ្រប់គ្រាន់ ។ ( កឋាខ័ណ្ឌទី ៣-៦-៩-១១)<br>**គោលការណ៍ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា ( ១៩៩០)**<br>- ស្ថាប័នអយ្យការត្រូវតែដាច់ដោយ ឡែកពីតុលាការ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែលច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារការគោរពសិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ភស្តុតាងដែលខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ១០-១៦) |
| | | **ស្តង់ដាទី ១១ :** តុលាការត្រូវធានាដល់សាធារណជននូវតម្លាភាពនិងការអាចប្រើប្រាស់បាន | **ក្រមនីតិវិធីព្រហទណ្ឌ**<br>**-បញ្ជីនៃពាក្យបណ្តឹង :** នៅតាមតុលាការជាន់ដំបូងនីមួយៗត្រូវបង្កើតឱ្យមានបញ្ជី អយ្យការមួយ សម្រាប់ចុះបណ្តឹងដែលប្តឹងដោយផ្ទាល់ដល់ព្រះរាជអាជ្ញា ឬបញ្ជូនមកដោយមន្ត្រីនគរបាលយុត្តិធម៌ ។ ( មាត្រា ៥០)<br>- ប្រធានតុលាការ ត្រូវបង្កើតឱ្យមានប្រព័ន្ធបែងចែករឿងក្តីប្រចាំឆ្នាំនៅក្នុងតុលាការ ។ ( មាត្រា ៥១)<br>- ការបែងចែកសំណុំរឿងដោយប្រធានតុលាការកាលណាមាន ចៅក្រមស៊ើបសួរច្រើនរូបនៅក្នុងតុលាការមួយ ។ | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ ( មាត្រា ១០)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ ( ១៩៦៦)**<br>-ភាពស្មើគ្នានៅក្នុងតុលាការ រួមទាំងសិទ្ធិស្មើគ្នានៅក្នុងតុលាការ និងសិទ្ធិទទួលបានព័ត៌មាននៅក្នុងភាសាដែលអាចធ្វើបាន ។ ( មាត្រា ១៤-៣-ក) |

| | | | | |
|---|---|---|---|---|
| | | | (មាត្រា ៥២)<br>- **ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួនៈ** ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើម នៃការ ឃាត់ខ្លួនមកនោះ បុគ្គល ដែលឃាត់ខ្លួនអាចសុំសន្ទនា ជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះ មានការ ទាក់ទិន នៅ ក្នុងរឿងជាមួយ ។ ជននេះត្រូវបាន ទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាម គ្រប់ មធ្យោបាយ និងជាបន្ទាន់ ។ (មាត្រា ៩៨)<br>- **ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីៈ** ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ ។ (មាត្រា ១៥០) | |
| **រដ្ឋប្បវេណី** | | **ស្តង់ដាទី4:** ទទួលបាននូវការ កាត់សេចក្តីនៅក្នុងរយៈមួយដ៏សម ស្រប | **ក្រមនីតិវិធីរដ្ឋប្បវេណី**<br>ប្រធានតុលាការ ត្រូវបង្កើតឱ្យមានប្រព័ន្ធបែងចែករឿងក្តីប្រចាំឆ្នាំនៅក្នុងតុលាការ ។ (មាត្រា ២៦)<br>**ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា**<br>- ចៅក្រមបំពេញភារកិច្ចតុលាការ និងរដ្ឋបាល ។ ចៅក្រមត្រូវត្រួតពិនិត្យ និង ណែនាំ ការងាររបស់បុគ្គលិកតុលាការ ឬបុគ្គលិកអយ្យការ ដោយវិរិយភាព ( មាត្រា ៣២)<br>-តុលាការមានប្រព័ន្ធ និងការរៀបចំ ដើម្បីធានានូវការប្រើប្រាស់ ឱ្យមានប្រសិទ្ធភាព ដោយចៅក្រម និង ព្រះរាជអាជ្ញា ( មាត្រា ៣១ និងមាត្រា ៣៣) | **អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)**<br>- ផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ គឺជាមូលដ្ឋាន នៃបញ្ហាក្នុងការសម្រេច ដោយគ្មានការ ពន្យាពេល ។ (មាត្រា ៤០-២-ខ-ii និងមាត្រា ៤០-២-ខ- iii) |

| | | | | |
|---|---|---|---|---|
| | | **ស្តង់ដាទី 5 :** តុលាការមានសមត្ថកិច្ច | **ក្រមនីតិវិធីរដ្ឋប្បវេណី**<br>ប្រធានតុលាការ ត្រូវបង្កើតឱ្យមានប្រព័ន្ធបែងចែករឿងក្តីប្រចាំឆ្នាំនៅក្នុងតុលាការ ។ ( មាត្រា ២៦)<br>- **ការពិនិត្យពាក្យបណ្តឹង:** តុលាការត្រូវកំណត់ អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះ ចំពោះពាក្យបណ្តឹងនោះ ក្នុងអំឡុងពេលនោះ ។ ( មាត្រា ៨៨) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>- -ដំណោះស្រាយដែលមានប្រសិទ្ធិភាព និងយុត្តិធម៌ព្រមទាំងសវនាការ ជាសាធារណៈ ។ ( មាត្រា៨ -មាត្រា១០)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និងគ្មានការរើសអើង ។ ( មាត្រា ១៤-១ , និងមាត្រា ២៦)<br>**គោលការណ៍ជាមូលដ្ឋានស្តីពី ឯករាជ្យភាពរបស់តុលាការ (១៩៨៥)**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និង បុគ្គល ។ នីតិវិធីត្រូវតែដំណើរការដោយយុត្តិធម៌ ។ ចៅ ក្រមត្រូវមានសេរីភាពក្នុងការបង្កើតសមាគម ។ អាណត្តិ របស់ចៅក្រមត្រូវតែធានាដោយច្បាប់គ្រប់គ្រាន់ ។ ( កឋាខ័ណ្ឌទី ៣-៦-៩-១១) |
| | | **ស្តង់ដាទី11 :** តុលាការត្រូវធានាដល់សាធារណជននូវតម្លាភាពនិងការអាចប្រើប្រាស់បាន | **ក្រមនីតិវិធីរដ្ឋប្បវេណី :**<br>-សិទ្ធិទទួលបាននូវការដោះស្រាយវិវាទរដ្ឋប្បវេណី តាមផ្លូវតុលាការ ត្រូវបានធានា ( មាត្រា ២)<br>-សិទ្ធិទាមទារឱ្យសាកសួរ នៅចំពោះមុខ : តុលាការត្រូវគោរព គោលការណ៍ ចំពោះមុខ ។ ( មាត្រា ៣)<br>-តុលាការត្រូវទទួលខុសត្រូវក្នុងការអនុវត្តបណ្តឹងរដ្ឋប្បវេណីឱ្យមានភាពយុត្តិធម៌ និងឆាប់រហ័ស ។ ( មាត្រា ៤) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ ( មាត្រា ១០)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>-ភាពស្មើគ្នានៅក្នុងតុលាការ រួមទាំងសិទ្ធិស្មើគ្នានៅក្នុងតុលាការ និងសិទ្ធិទទួលបានព័ត៌មាននៅក្នុងភាសាដែលអាចធ្វើបាន ។ ( មាត្រា ១៤-៣-ក) |

| | | | | |
|---|---|---|---|---|
| | | | ប្រធានតុលាការ ត្រូវបង្កើតឱ្យមានប្រព័ន្ធបែងចែករឿងក្តីប្រចាំឆ្នាំនៅក្នុងតុលាការ ។ ( មាត្រា ២៦) | |
| រដ្ឋបាល | | | ត្រូវពន្យល់ឱ្យបានពិស្តារ នៅពេលមានច្បាប់ពិសេស | |
| ពាណិជ្ជកម្ម | | | ត្រូវពន្យល់ឱ្យបានពិស្តារ នៅពេលមានច្បាប់ពិសេស | |
| សង្គម | | | ត្រូវពន្យល់ឱ្យបានពិស្តារ នៅពេលមានច្បាប់ពិសេស | |

## ដំណាក់កាលនៃដំណើររឿងក្តី

## ដំណាក់កាលទី៤_ ការរៀបចំរឿងក្តី /(ការស៊ើបអង្កេតរបស់ចៅក្រមស៊ើបសួរ)

| ប្រភេទរឿងក្តី | ទិសដៅ | ស្តង់ដា | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់និង បទបញ្ញត្តិ ជាតិ | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់ និង បទបញ្ញត្តិអន្តរជាតិ |
|---|---|---|---|---|
| ទូទៅ | -តុលាការ ត្រូវតែជាកន្លែងដែលប្រជាពលរដ្ឋអាចប្រើប្រាស់បាន<br>-តុលាការមានដំណើរការប្រកបដោយតម្លាភាព<br>-ចៅក្រមសម្រេចសេចក្តី ដោយឯករាជ្យ<br>- មន្ត្រីតុលាការ ត្រូវមានជំនាញវិជ្ជាជីវៈនិងមានការយល់ដឹងគ្រប់គ្រាន់<br>-មន្ត្រីតុលាការ បម្រើការងារដោយគោរពក្រមសីលធម៌<br>- ដំណើរការតុលាការ ត្រូវបានធ្វើឡើងដោយមិនលំអៀងយុត្តិធម៌និងប្រកបដោយ វិជ្ជាជីវៈ | **ស្តង់ដាទី5 :** តុលាការមានសមត្ថកិច្ច | -តុលាការមានបុគ្គលិកដែលមានសមត្ថភាពដែលអាចទទួលពាក្យបណ្តឹងប្រជាពលរដ្ឋបាន (ក្រម នីតិវិធីព្រហ្មទណ្ឌមាត្រា ៤ និងមាត្រា ៥)<br>-តុលាការមានបុគ្គលិកដែលមានសមត្ថភាព អាចវាយតម្លៃលើពាក្យបណ្តឹងរបស់ ប្រជាពលរដ្ឋ ថាតើពាក្យបណ្តឹងនោះត្រូវនឹងយុត្តាធិការរបស់តុលាការ (ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៧-២២)<br>-តុលាការត្រូវបានរៀបចំឡើង ដើម្បីឱ្យពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋអាចចុះ បញ្ជី និងអាចតាមដានបាន (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥០ និង មាត្រា ៧៥ , និងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦)<br>-តុលាការមានបុគ្គលិកដែលមានសមត្ថភាព អាចចាត់ចែងរឿងក្តី ដើម្បីកំណត់ បញ្ហាឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៤៧-៣៦៤ និងក្រមនីតិវិធីរដ្ឋប្បវេណី គន្ថី ទី ២ ជំពូកទី ៥ : | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធមនុស្ស (១៩៤៨)**<br>-ដំណោះស្រាយដែលមានប្រសិទ្ធិភាព និងយុត្តិធម៌ ព្រមទាំងសវនាការ ជាសាធារណៈ។ (មាត្រា៨ -មាត្រា១០)<br>**កតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ។ (មាត្រា ១៤-១)<br>**គោលការណ៍ជាមូលដ្ឋាន ស្តីពីឯករាជ្យភាពក្នុងប្រព័ន្ធ តុលាការ ឆ្នាំ ១៩៨៥**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និង បុគ្គល។ នីតិវិធីត្រូវតែដំណើរការដោយយុត្តិធម៌។ ចៅ ក្រមត្រូវមានសេរីភាព ក្នុងការបង្កើតសមាគម។ អាណត្តិ របស់ចៅក្រមត្រូវតែធានាដោយច្បាប់គ្រប់គ្រាន់។ (កឋាខ័ណ្ឌទី ៣-៦-៩-១១) |

| | | | | |
|---|---|---|---|---|
| | -គូវិវាទមានតំណាងដែលមានប្រសិទ្ធភាព<br>-តុលាការមានដំណើរការប្រកបដោយសមត្ថភាពនិងប្រសិទ្ធិភាព | | ការសម្រេចសេចក្តី)<br>-តុលាការមានសមត្ថភាពដែលអាចធានាថា សេចក្តីសម្រេច ត្រូវបានតាមដាន ដោយត្រឹមត្រូវ ( ក្រមនីតិវិធីរដ្ឋប្បវេណី គន្ថីទី ៦ : ការអនុវត្តដោយបង្ខំ , គន្ថីទី ៣ ជំពូកទី ២ : បណ្តឹងឧទ្ធរណ៍ , គន្ថីទី ៥ ជំពូកទោល : នីតិវិធីដាស់តឿន)<br>-តុលាការត្រូវរៀបចំឡើង ដើម្បីធានាសេចក្តីសម្រេច ត្រូវបានធ្វើឡើងយ៉ាង លឿន និងការបិទ ដោយត្រឹមត្រូវ ( ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៥៨, ៣៧៦, ៣៨១ និងមាត្រា ៣៨២ , ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦៤ , គន្ថីទី ៣ ជំពូកទី ១ ( បទបញ្ញត្តិទូទៅ) និងជំពូកទី ២ (បណ្តឹងឧទ្ធរណ៍) , មាត្រា ៣៧៦, ៣៨១, ៣៨២ និងមាត្រា ៣៨៦ )<br>-ចៅក្រមបំពេញភារកិច្ចតុលាការ និងរដ្ឋបាល ។ ចៅក្រមត្រូវត្រួតពិនិត្យ និង ណែនាំ ការងាររបស់បុគ្គលិកតុលាការ ឬបុគ្គលិកអយ្យការ ដោយវិរិយភាព ( ក្រមសីលធម៌ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣២)<br>-តុលាការមានប្រព័ន្ធ និងការរៀបចំ ដើម្បីធានានូវការប្រើប្រាស់ ឱ្យមានប្រសិទ្ធភាព ដោយចៅក្រម និងព្រះរាជអាជ្ញា ( ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣១ និងមាត្រា ៣៣) | **គោលការណ៍ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា ( ១៩៩០)**<br>-ភាពមិនលំអៀងនៃការជ្រើសរើសព្រះរាជអាជ្ញា និង ការបណ្តុះបណ្តាលព្រះរាជអាជ្ញាដែលត្រឹមត្រូវ ។ ព្រះរាជ អាជ្ញាត្រូវបំពេញតួនាទីដោយវិជ្ជាជីវៈ និងផ្តល់សេវា សមហេតុ សមផល ។ ស្ថាប័នអយ្យការត្រូវតែដាច់ដោយ ឡែកពីតុលាការ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែល ច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារការគោរពសិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ ភស្តុតាងដែល ខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ២-៣-៦-១០-១៦)<br>**គោលការណ៍បឹងហ្គាឡូ ស្តីពីក្រមសីលធម៌របស់ចៅក្រម** (២០០២)<br>-ការបំពេញមុខងារនៅក្នុងស្ថាប័នតុលាការ ត្រូវតែមាន សមត្ថភាព និងវិរិយភាព ។ ( តម្លៃទី ៦) |

| | | | | |
|---|---|---|---|---|
| | | **ស្តង់ដាទី 6 :** តុលាការ ឯករាជ្យ | **រដ្ឋធម្មនុញ្ញ**<br>តុលាការឯករាជ្យ ( មាត្រា ១២៨-ថ្មី)<br>**ច្បាប់ព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់**<br>- តុលាការឯករាជ្យ( មាត្រា ១-១)<br>**ក្រមសីលធមិ ចៅក្រម និងព្រះរាជអាជ្ញា**<br>ចៅក្រមនិងព្រះរាជអាជ្ញាត្រូវប្រកាន់ខ្ជាប់នូវគោលការណ៏ឯករាជភាព។(ជំពូក២: មាត្រា ២-៦) | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធមនុស្ស (១៩៤៨)**<br>-សវនាការដោយយុត្តិធមិ និងជាសាធារណៈដោយតុលាការឯករាជ។(មាត្រា ១០)<br>**គោលការណ៏ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលា ការ (១៩៨៥)**<br>-ឯករាជ្យភាពរបស់តុលាការត្រូវបានធានា មិនត្រូវបាន មានការជ្រៀតជ្រែក ការប្រើប្រាស់នូវនីតិវិធីច្បាប់ ត្រូវ បានផ្តល់ឱ្យនូវធនធានគ្រប់គ្រាន់ ការជ្រើសរើស និង ការបណ្តុះបណ្តាលដោយត្រឹមត្រូវ ធានានូវអាណត្តិរបស់ ចៅក្រម ការតំឡើងឋានៈ ដោយមិនលំអៀង ការចាត់ ចែងរឿងក្តីផ្ទៃក្នុង និងតុលាការ ត្រូវប្រកាន់ភ្ជាប់នូវ គោលការណ៏សំងាត់វិជ្ជាជីវៈ។(កឋាខ័ណ្ឌទី ១-៤-៥-៧-៨-១០-១២-១៥)<br>**គោលការណ៏ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា (១៩៩0)**<br>-ព្រះរាជអាជ្ញាត្រូវបានការពារ នៅពេលត្រូវបានគំរាម កំហែងក្នុងពេលបំពេញការងារ មានសិទ្ធិចូលរួមក្នុង សមាគម។ ស្ថាប័នអយ្យការត្រូវតែដាច់ដោយ ឡែកពីតុលាការ។ ព្រះរាជអាជ្ញានិងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីយ៉ាងសកម្ម ក្នុងរឿងព្រហ្មទណ្ឌ ដែល ច្បាប់ផ្តល់អោយ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារ ការគោរពសិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្តដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ ភស្តុតាងដែលខុសច្បាប់។(កឋាខ័ណ្ឌទី ៤-៥-៦-៩-១០-១៦) |

| | | | | |
|---|---|---|---|---|
| | | **ស្តង់ដាទី 7 :** តុលាការមិន លំអៀង | **រដ្ឋធម្មនុញ្ញ**<br>តុលាការឯករាជ្យ ( មាត្រា ១២៨-ថ្មី)<br>**ច្បាប់ព្រហ្មទណ្ឌអន្តរកាលអ៊ុនតាក់**<br>- ចៅក្រុមត្រូវសំរេចសេចក្តីដោយមិនលំអៀង ផ្អែកលើ អង្គ ហេតុនិងអង្គច្បាប់( មាត្រា ១)<br>**ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា**<br>ចៅក្រមនិងព្រះរាជអាជ្ញាត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ អនាគតិ ។ (ជំពូក៣: មាត្រា ៧-១៧) | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈដោយតុលាការ ឯករាជ ។ ( មាត្រា ១០)<br>**គោលការណ៍ជាមូលដ្ឋាន ស្តីពីឯករាជ្យភាពក្នុងប្រព័ន្ធ តុលាការ ឆ្នាំ ១៩៨៥**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និង បុគ្គល ។ នីតិវិធីត្រូវតែដំណើរការដោយយុត្តិធម៌ ។ ចៅ ក្រមត្រូវមាន សេរីភាពក្នុងការបង្កើតសមាគម ។ អាណត្តិ របស់ចៅក្រម ត្រូវតែធានាដោយច្បាប់គ្រប់គ្រាន់ ។ ( កឋាខ័ណ្ឌទី ៣-៦-៩-១១)<br>**គោលការណ៍ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា ( ១៩៩០)**<br>-ភាពមិនលំអៀងនៃការជ្រើសរើសព្រះរាជអាជ្ញា និង ការបណ្តុះ បណ្តាលព្រះរាជអាជ្ញាដែលត្រឹមត្រូវ ។ ព្រះរាជ អាជ្ញាត្រូវបំពេញ តួនាទីដោយវិជ្ជាជីវៈ និងផ្តល់សេវា សមហេតុសមផល ។ ស្ថាប័ន អយ្យការត្រូវតែដាច់ដោយ ឡែកពីតុលាការ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងរឿង ព្រហ្មទណ្ឌ ដែល ច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និងស្ថាប័ន អយ្យការ ត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារការគោរព សិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ ភស្តុតាងដែលខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ២-៣-៦-១០-១៦) |
| ព្រហ្មទណ្ឌ | | **ស្តង់ដាទី1 :** វិធានការចាប់ បង្ខំក្នុងនីតិវិធីព្រហ្មទណ្ឌ | **ក្រមនីតិវិធីព្រហទណ្ឌ:**<br>**ការឃាត់ខ្លួន ( មាត្រា ៩៦)** | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធមនុស្ស ( ១៩៤៨)**<br>- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន |

| | | | | |
|---|---|---|---|---|
| | | ត្រូវមានការយល់ព្រមពី តុលាការ | - ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង **ការឃាត់ខ្លួនដោយ** មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។<br>- ការពន្យារពេលឃាត់ខ្លួនត្រូវសុំទៅព្រះរាជអាជ្ញា។ ការពន្យារនេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោងឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន ។ ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនីតិជន។<br>- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ ខ្លួន ហួសរយៈពេល ៣៦ ម៉ោងឡើយ ។<br>- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៤៨ ម៉ោងឡើយ ។<br>- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ២៤ ម៉ោងឡើយ ។<br>- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៣៦ ម៉ោងឡើយ ។<br>- អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេ | ឬការនិរទេសខ្លួន លុះត្រាណាតែមានច្បាប់អនុញ្ញាតិ។ (មាត្រា ៩)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>- ត្រូវបានជូនដំណឹងភ្លាមអំពីការចោទប្រកាន់ និងត្រូវនាំខ្លួន ភ្លាមមក ឱ្យចៅក្រម។ ត្រូវចាត់ទុកថាគ្មានទោស។ មាន សមត្ថភាពក្នុងការពិនិត្យសាក្សី។ សេរីភាពរួចផុត ពីការ ធ្វើទារុណកម្ម។ (មាត្រា ៧ មាត្រា ៩ មាត្រា ១៤-២ មាត្រា ១៤-៣-ង មាត្រា ១៥) |

| | | | | |
|---|---|---|---|---|
| | | | ឃាត់ខ្លួនបានឡើយ ។<br>**វិធានអនុវត្តចំពោះការឆែកឆេរ( មាត្រា ១៥៩)**<br>-ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សី ២ (ពីរ) នាក់ ដែលខ្លួនចាត់តាំង ។<br>-ការឆែកឆេរនៅក្នុងការិយាល័យមេធាវី ត្រូវធ្វើនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវីនោះ ។<br>-ចៅក្រមស៊ើបសួរមិនអាចផ្ដើមឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨(ដប់ប្រាំបី) ល្ងាច។<br>**ការបិទស្លាកបោះត្រាលើវត្ថុតាង ( មាត្រា ១៦០)**<br>- ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាង ។ ចៅក្រមស៊ើបសួរ ត្រូវតែបិទស្លាកបោះត្រាលើវត្ថុតាង ។<br>- កំណត់ហេតុស្ដីពីការចាប់នេះ ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី រួមជាមួយ អ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ (ពីរ) នាក់ ។<br>- ការប្រគល់វត្ថុដែលចាប់យក ឱ្យទៅម្ចាស់ដើមវិញដោយចៅក្រមស៊ើបសួរ ។ ប៉ុន្តែ វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិដូចជាអាវុធ ឬជាតិផ្ទុះព្រមទាំងវត្ថុដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវប្រគល់សងទៅឱ្យសាមីខ្លួនបានទេ ។ វត្ថុទាំងនេះត្រូវរឹបអូសជាកម្មសិទ្ធិរបស់រដ្ឋ ។ ( មាត្រា ១៦១) | |

| | | | | |
|---|---|---|---|---|
| | | | - **ដីកាបង្គាប់ឱ្យនាំខ្លួន:** តុលាការមានសមត្ថភាពចាំបាច់ដើម្បីចេញដីកាបង្គាប់ឱ្យនាំខ្លួនដែលមានគុណភាពខ្ពស់, ទាន់ពេលវេលា, និងឆាប់រហ័សទៅឱ្យអាជ្ញាធរពាក់ពន្ធ័ត្រឹមត្រូវ មុនសវនា ការ ។ ( មាត្រា ១៨៩ ដល់ មាត្រា ១៩៤)<br>- **ដីកាបង្គាប់ឱ្យចាប់ខ្លួន:** តុលាការមានសមត្ថភាពចាំបាច់ដើម្បីចេញដីកាបង្គាប់ឱ្យចាប់ខ្លួនដែលមានគុណភាពខ្ពស់, ទាន់ពេលវេលា, និងឆាប់រហស័ទៅឱ្យអាជ្ញាធរពាក់ពន្ធ័ត្រឹមត្រូវមុនសវនា ការ ។ ( មាត្រា ១៩៥ ដល់ មាត្រា ២០២)<br>- **ការឃុំខ្លួនបណ្ដោះអាសន្ន:** តុលាការមានសមត្ថភាពចាំបាច់ដើម្បីចេញដីកាឃុំខ្លួនបណ្ដោះអាសន្ន ដែលមានគុណភាពខ្ពស់, ទាន់ពេលវេលា, និងឆាប់រហស័ទៅឱ្យអាជ្ញាធរពាក់ពន្ធ័ត្រឹមត្រូវមុនសវនាការ ព្រមទាំងផ្ដល់ពត័មានដល់ជនត្រូវចោទនិងមេធាវីរបស់គាត់ ។ ( មាត្រា ២០៣ ដល់ មាត្រា២១៨)<br>- **ដីកាបង្គាប់ឱ្យឃុំខ្លួន:** តុលាការមានសមត្ថភាពចាំបាច់ដើម្បីចេញដីកាបង្គាប់ឱ្យឃុំខ្លួនដែលមានគុណភាពខ្ពស់, ទាន់ពេលវេលា, និងឆាប់រហស័ទៅឱ្យអាជ្ញាធរពាក់ពន្ធ័ត្រឹមត្រូវមុនសវនាការ ។ ( មាត្រា ២១៩ ដល់ មាត្រា ២២២)<br>- **ការត្រួតពិនិត្យតាមតុលាការ:** តុលាការមានសមត្ថភាព | |

| | | | | |
|---|---|---|---|---|
| | | | ចាំបាច់ ដើម្បីចេញដីកាដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់តុលាការដែលមានគុណភាពខ្ពស់, ទាន់ពេលវេលា, និងឆាប់រហ័សទៅឱ្យអាជ្ញាធរពាក់ពន្ធ័ត្រឹមត្រូវ មុនសវនាការ ។ ( មាត្រា ២២៣ ដល់ មាត្រា ២៣០) | |
| | | **ស្តង់ដាទី2:** មានឱកាស ស្មើៗគ្នាក្នុងការការពារខ្លួន | **ក្រមនីតិវិធីព្រហទណ្ឌ:**<br>**ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន:** ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើម នៃការឃាត់ខ្លួន មកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំ សន្ទនាជាមួយមេធាវី ឬជាមួយជនណា ម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការ ទាក់ទិន នៅ ក្នុងរឿងជាមួយ ។ ជននេះត្រូវបាន ទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់ មធ្យោបាយ និងជាបន្ទាន់ ។ ( មាត្រា ៩៨)<br>-**ការជូនដំណឹងអំពីការចោទប្រកាន់:** ចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់ជនត្រូវចោទអំពីសិទ្ធិរបស់គាត់ ដូចជាសិទ្ធិក្នុងការឆ្លើយ សិទ្ធិក្នុងការមិនឆ្លើយ សិទ្ធិមានមេធាវី និង សិទ្ធិមានអ្នកបកប្រែ ។ ( មាត្រា ១៤៣ ដល់ មាត្រា ១៤៤)<br>- **ការសួរចម្លើយជនត្រូវចោទ:** ជនត្រូវចោទត្រូវបានសួរចម្លើយតែនៅចំពោះមុខមេធាវីរបស់គាត់ប៉ុណ្ណោះ ។ ចៅក្រមស៊ើបសួរត្រូវអញ្ជើញមេធាវីយ៉ាងហោចណស់ក៏ ៥ ថ្ងៃមុនកាលបរិច្ឆេទនៃការសួរចម្លើយ ។ ( មាត្រា ១៤៥- | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស ( ១៩៤៨)**<br>- ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ឬការនិរទេសខ្លួន លុះត្រាណាតែមានច្បាប់អនុញ្ញាតិ ។ ( មាត្រា ៩)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ( ១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ ។ ( មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ ( ១៩៦៦)**<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើម កំណើតជាតិសាសន៍ ។ ( មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ( ១៩៨៩)**<br>-ការធានានូវសិទ្ធិរបស់កុមារ រួម ទាំងសិទ្ធិមានអ្នកបកប្រែ ។ ( មាត្រា ២-១ , ) |

| | | | | |
|---|---|---|---|---|
| | | | មាត្រា ១៤៩)<br>- **ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី:** ចៅក្រមស៊ើបសួរត្រូវអញ្ជើញមេធាវីយ៉ាងហោចណាស់ក៏ ៥ ថ្ងៃមុនកាលបរិច្ឆេទនៃការស្តាប់ចម្លើយ ។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវអមដោយមេធាវី ។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវ បានស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់គាត់ប៉ុណ្ណោះ ។ ( មាត្រា១៥០-មាត្រា ១៥២)<br>- **ការស្តាប់ចម្លើយសាក្សី:** ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយ បុគ្គលគ្រប់រូបដែលចម្លើយនោះអាចមានប្រយោជន៍នៅក្នុងការសំដែងឱ្យឃើញការពិត ។ ( មាត្រា ១៥៣-មាត្រា ១៥៨)<br>- កោសលវិច័យ ( មាត្រា ១៦២-មាត្រា ១៧៧)<br>  - ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី ។ ( មាត្រា ១៦២)<br>  - ជនត្រូវចោទអាចសុំឱ្យអ្នកជំនាញស្តាប់ចម្លើយរបស់ខ្លួននៅចំពោះមុខមេធាវី ។ ( មាត្រា ១៦៧)<br>- **ការជូនដំណឹងអំពីសេចក្តីសន្និដ្ឋាននៃកោសលវិច័យ:** កាលណារបាយការណ៍កោសលវិច័យត្រូវបានធ្វើរួចហើយ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានដល់ព្រះរាជអាជ្ញា ។ របាយការណ៍កោសលវិច័យត្រូវដាក់ចូលក្នុងសំណុំរឿងស៊ើបសួរ ។ចៅក្រមស៊ើបសួរកោះហៅជនត្រូវចោទ និង | |

| | | | | |
|---|---|---|---|---|
| | | | មេធាវី ដើម្បីប្រាប់ឱ្យដឹងពីសេចក្តីសន្និដ្ឋាននៃកោសល វិច័យនេះ ។ ចៅក្រមស៊ើបសួរអាចកោះ ហៅដើមបណ្តឹង រដ្ឋប្បវេណី និងមេធាវីផងដែរ ដើម្បីប្រាប់ឱ្យដឹងពីសេចក្តី សន្និដ្ឋាននៃកោសលវិច័យ ។ចៅក្រមស៊ើបសួរកំណត់ រយៈពេលដែលអនុញ្ញាតឱ្យព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីដាក់ពាក្យសុំធ្វើកោសល វិច័យ បន្ថែម ឬប្រតិកោសលវិច័យ ។ ( មាត្រា ១៧០) | |
| | | **ស្តង់ដាទី4:** ទទួលបាននូវការ កាត់ សេចក្តីនៅក្នុងរយៈ ពេល មួយ ដ៏សមស្រប | **ក្រមនីតិវិធីព្រហ្មទណ្ឌ:**<br>**ការឃាត់ខ្លួន( មាត្រា ៩៦)**<br>- មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែល សង្ស័យថា បានចូលរួមកនុងបទល្មើស ។<br>- មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូន ព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាង ទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។<br>- ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាព នគរបាល ឬកងរាជអាវុធហត្ថ ។<br>- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈ ពេល ៣៦ ម៉ោងឡើយ ។<br>- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈ | **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-សវនាការដោយគ្មានការពន្យាពេលត្រឹមត្រូវ ។ ( មាត្រា ១៤-៣-គ) |

| | | | | |
|---|---|---|---|---|
| | | | ពេល ២៤ ម៉ោងឡើយ ។<br>- ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៤៨ ម៉ោងឡើយ ។<br>- ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួន ហួសរយៈពេល ៣៦ ម៉ោងឡើយ ។<br>- អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។<br><br>- ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីៈ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុតវេលានេះមេធាវីអាចពិនិត្យសំណុំរឿង នៃនីតវិ ធីបាន ។៥ ( ប្រាំ ថ្ងៃ មុនការស្តាប់ចម្លើយ ។<br>**( មាត្រា ១៥០)**<br>- ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី៦ ( ប្រាំមួយ) ខែ បានទេ ។ ប៉ុន្តែ នៅពេលផុតចិរវេលានេះចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ៦ ( ប្រាំមួយ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខន្លួ បណ្តោ ះអាសនច្ន ានតែ ២ ( ពីរ) | |

| | | | | |
|---|---|---|---|---|
| | | | ដងគត់ ។( **មាត្រា ២០៨**)<br>- ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤( បួន) ខែ បានទេ ។ ប៉ុន្ដែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើប សួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែ ម្ដងគត់មិនឱ្យលើសពី ២ ( ពីរ) ខែដោយដីកាមានសំអាង ហេតុត្រឹមត្រូវនិងច្បាស់លាស់ ។( **មាត្រា ២០៩**)<br>-ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំង មនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ឬបទឧក្រិដ្ឋ សង្គ្រាម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ១ ( មួយ) ឆ្នាំបានទេ ចំពោះបទល្មើសនីមួយៗ ។ ប៉ុន្ដែ នៅពេលផុត ថិរវេលានេះចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួន បណ្ដោះ អាសន្នម្ដងបាន ១ ( មួយ) ឆ្នាំ ដោយដីកា មាន សំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។ចៅក្រម ស៊ើប សួរអាចបង្គាប់ឱ្យពន្យារការឃុំខ្លួនបណ្ដោះអាសន្ននេះបាន តែ ២ ( ពីរ) ដងគត់ ។( **មាត្រា ២១០**)<br>- អនីតិជនអាយុតិចជាង ១៤ ( ដប់បួន) ឆ្នាំ មិនអាចត្រូវ ឃុំខ្លួនបណ្ដោះអាសន្នទេ ។ចៅក្រមស៊ើបសួរអាចសម្រេច ប្រគល់អនីតិជននេះឱ្យឪពុកម្ដាយ អ្នកអាណាព្យាបាល ឬក្នុងករណីគ្មានអាណាព្យាបាល ត្រូវប្រគល់ទៅ មជ្ឈមណ្ឌលអប់រំថែរក្សាបណ្ដោះអាសន្ន រង់ចាំសេចក្ដី | |

| | | | | |
|---|---|---|---|---|
| | | | សម្រេចរបស់តុលាការ ។(**មាត្រា ២១២**)<br>- ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទ ប្រកាន់ពីបទឧក្រិដ្ឋ ថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ(**មាត្រា ២១៣**) :<br>១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះ មានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។<br>២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ កាលណាអនីតិជននេះ មានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។<br><br>- ចំពោះអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងត្រូវចោទប្រកាន់ពីបទមជ្ឈិម ថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ(**មាត្រា ២១៤**) :<br>១-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ (ពីរ) ខែ បានទេ កាលណាអនីតិជននេះ មានអាយុតិចជាង ១៦ (ដប់ប្រាំមួយ) ឆ្នាំ ។<br>២-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ កាលណាអនីតិជននេះ មានអាយុចាប់ពី ១៦ | |

| | | | | |
|---|---|---|---|---|
| | | | (ដប់ប្រាំមួយ) ឆ្នាំ ដប់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។<br>- អនីតិជនអាយុតិចជាង ១៤ (ដប់បួន) ឆ្នាំ មិនអាចត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ បានទេ ។(**មាត្រា ២២៤**)<br>**ដីកាដំណោះស្រាយ ( មាត្រា ២៤៧)**<br>-ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមដីកាដំណោះស្រាយ ។ ដីកានេះ អាចជាដីកាបញ្ជូនទៅជំនុំជម្រះ ឬដីកាលើក លែង ចោទប្រកាន់ ។ ( មាត្រា ២៤៧-១)<br>- ដីកាដំណោះស្រាយត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី ។ ( មាត្រា ២៤៧-៥)<br>- សេចក្ដីសម្រេចរក្សាទុកជនត្រូវចោទក្នុងឃុំជាបណ្ដោះអាសន្ន លែងមានអានុភាពក្នុងរយៈពេល៤ ( បួន) ខែ ។ ប្រសិនបើជនត្រូវចោទមិនបានចូលទៅបង្ហាញខ្លួននៅមុខតុលាការក្នុងរយៈពេល ៤( បួន) ខែនោះទេ ជនត្រូវចោទនេះត្រូវបានដោះលែងឱ្យនៅក្រៅឃុំបណ្ដោះអាសន្នដោយឯកឯង ។ ( មាត្រា២៤៩-៣)<br>**- ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅតុលាការដើម្បីកំណត់ពេលសវនាការជំនុំជម្រះ ប្រសិនបើខ្លួនចេញ ដីការសំរេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ។ ( មាត្រា ២៥០)**<br>**-រយៈពេលដែលត្រូវគោរពរវាង ការប្រគល់ដីកាកោះហៅ** | |

| | | | | |
|---|---|---|---|---|
| | | | **បញ្ជូនទៅជំនុំជម្រះផ្ទាល់ឱ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យ ចូលបង្ហាញខ្លួននៅមុខតុលាការត្រូវកំណត់ដូចតទៅ (មាត្រា៤៥៧):**<br>-១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែន ដីនៃទីស្នាក់ការរបស់តុលាការជាន់ដំបូង<br>-២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែង មួយផ្សេងទៀតក្នុងដែនដីជាតិ<br>-២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា<br>-៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងទីកន្លែងដទៃ ផ្សេងទៀត ។<br><br>**-ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់អាចត្រូវ ប្រគល់ឱ្យជនជាប់ចោទដោយផ្ទាល់ដៃដោយព្រះរាជអាជ្ញា ។ (មាត្រា៤៥៨)**<br>**ដីការកោះត្រូវបញ្ជាក់ថាជនជាប់ត្រូវអមដោយមេធាវី ។ (មាត្រា ៤៦៥)**<br>**-រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឱ្យចូលបង្ហាញខ្លួន នៅមុខតុលាការ ត្រូវកំណត់ដូចតទៅ (មាត្រា ៤៦៦):**<br>-១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង | |

| | | | | |
|---|---|---|---|---|
| | | | -២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយ ផ្សេងទៀតនៃដែនដីជាតិ<br>-២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា<br>-៣ (បី) ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយ ផ្សេងទៀត ។<br>**ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា**<br>- ចៅក្រមបំពេញភារកិច្ចតុលាការ និងរដ្ឋបាល ។ ចៅក្រមត្រូវត្រួតពិនិត្យ និង ណែនាំ ការងាររបស់បុគ្គលិកតុលាការ ឬបុគ្គលិកអយ្យការ ដោយវិរិយភាព ( មាត្រា ៣២)<br>- ភារកិច្ចតុលាការនិងអយ្យការរបស់ចៅក្រមមានអាទិភាព ជាង ការងារនានាទាំងអស់ ។ ចៅក្រមគួរមានពេល វេលាគ្រប់ គ្រាន់ដើម្បី បំពេញភារកិច្ចអោយបានល្អ  ( មាត្រា ៣១) | |
| | | **ស្តង់ដាទី៩:** ត្រូវបានគេយកចិត្តទុកដាក់ដោយស្មើភាព | **ក្រមនីតិវិធីព្រហ្មទណ្ឌ:**<br>**ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន:** ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើម នៃការឃាត់ខ្លួន មកនោះ បុគ្គលដែលឃាត់ខ្លួនអាចសុំ សន្ទនាជាមួយមេធាវី ឬជាមួយជនណា ម្នាក់ដែលខ្លួនជ្រើសរើសកុំឱ្យតែជននេះមានការ ទាក់ទិន នៅ ក្នុងរឿងជាមួយ ។ ជននេះត្រូវបាន ទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះតាមគ្រប់ មធ្យោបាយ និងជាបន្ទាន់ ។ ( មាត្រា ៩៨) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និងត្រូវបានការពារដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដោយគ្មានការរើសអើង។ ( មាត្រា ២-១-២ , មាត្រា ៧ និង មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ |

| | | | | |
|---|---|---|---|---|
| | | | - **ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី:** ដើមបណ្តឹង រដ្ឋប្បវេណី អាចត្រូវ បានគេស្តាប់ចម្លើយតែនៅចំពោះមុខ មេធាវីរបស់ខ្លួនប៉ុណ្ណោះ ។ ( មាត្រា ១៥០)<br>- ការមើលសំណុំរឿង: មេធាវីអាចមើលសំណុំរឿងនៅការិយាល័យក្រឡាបញ្ជីនៃតុលាការក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី ។ ( មាត្រា ៣១៩) | ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និងគ្មានការរើសអើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យត្រូវបានការពារ ។ ( មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (១៩៦៦)**<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើម កំណើតជាតិសាសន៍ ។ ( មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)**<br>-ការធានានូវសិទ្ធិរបស់កុមារ និងសិទ្ធិរបស់កុមារដែល ត្រូវបានចោទប្រកាន់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ រួម ទាំងសិទ្ធិមានអ្នកបកប្រែ ។ ( មាត្រា ២-១ , មាត្រា ៤០-២-ខ-vi)<br>**អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការ រើសអើងប្រឆាំងនឹងស្ត្រីភេទ (១៩៧៩)**<br>-ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំង អស់នៃនីតិវិធីក្នុងតុលាការ និងវិធានការសមរម្យ ដើម្បី លុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។ ( មាត្រា ១៥-១ , មាត្រា ១៥-២ និងមាត្រា ១៦-១)<br>**គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា- ក្នុងនីតិវិធីព្រហ្មទណ្ឌ (១៩៩០)**<br>- ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែល ច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និង |

| | | | | |
|---|---|---|---|---|
| | | | | ស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារ ការគោរព សិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និងបដិសេធនូវវាល់ ភស្តុតាង ដែលខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ២-៣-៦-១០-១៦) |
| | | **ស្តង់ដាទី11 :** តុលាការត្រូវធានាដល់សាធារណៈជន នូវតម្លាភាព និងការអាចប្រើប្រាស់បាន | **ក្រមនីតិវិធីព្រហ្មទណ្ឌ:**<br>**ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន:** ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើម នៃការឃាត់ខ្លួន មកនោះ បុគ្គលដែលឃាត់ខ្លួនអាច សុំ សន្ទនាជាមួយមេធាវី ឬជាមួយជនណា ម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការ ទាក់ទិន នៅ ក្នុងរឿងជាមួយ ។ ជននេះត្រូវបាន ទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់ មធ្យោបាយ និងជាបន្ទាន់ ។ ( មាត្រា ៩៨)<br>- **ការស្តាប់ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី:** ដើមបណ្តឹង រដ្ឋប្បវេណី អាចត្រូវ បានគេស្តាប់ចម្លើយ តែនៅចំពោះមុខ មេធាវីរបស់ខ្លួនប៉ុណ្ណោះ ។ ( មាត្រា ១៥០)<br>- ភាពចាំបាច់នៃការធ្វើកោសលវិច័យ: ចៅក្រមស៊ើបអង្កេតអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញា របស់ជនត្រូវចោទ ឬ ដើមបណ្តឹងរដ្ឋប្បវេណី ។ ( មាត្រា ១៦២) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ ( មាត្រា ១០)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>-ភាពស្មើគ្នានៅក្នុងតុលាការ រួមទាំងសិទ្ធិស្មើគ្នានៅក្នុង តុលាការ និងសិទ្ធិទទួលបានព័ត៌មាននៅក្នុងភាសាដែល អាចធ្វើបាន។ ( មាត្រា ១៤-៣-ក) |
| **រដ្ឋប្បវេណី** | | **ស្តង់ដាទី4:** ទទួលបាននូវការ កាត់ | **ក្រមនីតិវិធីរដ្ឋប្បវេណី** | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស ( ១៩៤៨)** |

| | | | | |
|---|---|---|---|---|
| | | សេចក្ដីនៅក្នុងរយៈមួយដ៏សម ស្រប | -ជនគ្រប់រូបមានសិទ្ធិទទួលបាននូវការជំនុំជំរះក្នុងរឿងក្ដីរដ្ឋប្បវេណី ( មាត្រា ២)<br>- ប្រធានតុលាការ ត្រូវបង្កើតឱ្យមានប្រព័ន្ធបែងចែករឿងក្ដី ប្រចាំឆ្នាំនៅ ក្នុងតុលាការ ។ ( មាត្រា ២៦)<br>-សិទ្ធិរបស់ភាគីក្នុងការស្នើសុំអ្នកបកប្រែ ក្នុងករណីមិនចេះភាសា ខ្មែរ ( មាត្រា ៥ មាត្រា ៨០-១)<br>- របៀបដាក់ពាក្យបណ្ដឹងនិងចំណុចដែលត្រូវសរសេរក្នុងពាក្យបណ្ដឹង: ការប្ដឹងត្រូវធ្វើដោយដាក់ពាក្យបណ្ដឹង ជាលាយលក្ខណ៍អក្សរទៅតុលាការ ( មាត្រា៧៥)<br>- ការបញ្ជូនពាក្យបណ្ដឹង: ពាក្យបណ្ដឹងត្រូវបញ្ជូនទៅចុងចម្លើយជាចាំបាច់ ។ ( មាត្រា៧៩)<br>**- គោលការណ៍ទូទៅនៃការទាញហេតុផលដោយផ្ទាល់មាត់ និងការរៀបចំ ( មាត្រា ៨៩-មាត្រា ១០២)**<br>- ប្រធានក្រុមប្រឹក្សាជំនុំជំរះត្រូវដឹកនាំនីតិវិធីត្រៀមសំរាប់ការទាហហេតុផល និង ត្រូវដឹកនាំចាត់ចែងការទាញហេតុផលដោយផ្ទាល់មាត់ ។ ( មាត្រា ៨៩)<br>- តុលាការអាចសាកសួរឬឱ្យភាគីបំភ្លឺ ។ ភាគីក៏មានសិទ្ធិឱ្យតុលាការសួរសំណួរចាំបាច់ទៅភាគីម្ខាង ទៀត ។ ( មាត្រា ៩០)<br>- មធ្យោបាយតទល់ឬការពារខ្លួនត្រូវដាក់ឱ្យតុលាការនៅពេលណាមួយដែលសមរម្យតាមដំណើរការបណ្ដឹង ។ ( មាត្រា ៩៣) | **- ដំណោះស្រាយមានប្រសិទ្ធភាព**ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ឬការនិរទេសខ្លួន លុះត្រាណាតែមានច្បាប់អនុញ្ញាតិ ។  សិទ្ធិឯកជន ។ ( មាត្រា ៨-៩-១២)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ( ១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ ។ ( មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធមិ ( ១៩៦៦)**<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើម កំណើតជាតិសាសន៏ ។ ( មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ( ១៩៨៩)**<br>-ការធានានូវសិទ្ធិរបស់កុមារ រួម ទាំងសិទ្ធិមានអ្នកបកប្រែ ។ ( មាត្រា ២-១ , មាត្រា ៤០-២-ខ-vi)<br>**អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការ រើសអើងប្រឆាំងនឹងស្ត្រីភេទ ( ១៩៧៩)**<br>-ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំង អស់នៃនីតិវិធីក្នុងតុលាការ និងវិធានការសមរម្យ ដើម្បី លុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។ ( មាត្រា ១៥-១ , មាត្រា ១៥-២ និងមាត្រា ១៦- |

| | | | | |
|---|---|---|---|---|
| | | | - តុលាការមិនអាចយកអង្គហេតុណាដែលភាគីណាមួយមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។ ( មាត្រា ៩៥)<br>- តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀមនៅពេលធ្វើនីតិវិធីត្រៀមសំរាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាលលមាត់ ។ ( មាត្រា ១០១)<br>- តុលាការអាចកំណត់អំឡុងពេលដែលត្រូវដាក់ឯកសារត្រៀមលើកដំបូងរបស់ចុងចម្លើយ ។ ( មាត្រា ១០២)<br><br>**នីតិវិធីត្រៀមសំរាប់ការទាញហេតុផលដោយផ្ទាល់មាត់ ( មាត្រា ១០៣-១១២)**<br>- នៅក្នុងនីតិវិធីត្រៀមសំរាប់ការទាញហេតុផល តុលាការត្រូវរៀបចំនូវសេចក្តីអះអាងរបស់ភាគី បំភ្លឺនូវចំណុចវិវាទនៃរឿងក្តីដែលគូភាគីយល់មិនស្របគ្នា និងរៀបចំភស្តុតាងដែលទាក់ទងនឹងចំណុចវិវាទនៃរឿងក្តីនោះ ។ ( មាត្រា១០៣)<br>- នៅក្នុងនីតិវិធីត្រៀមសំរាប់ការទាញហេតុផល តុលាការត្រូវសាកល្បងផ្សះផ្សារ ។ ( មាត្រា១០៤)<br>- នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន ។ ( មាត្រា១០៥)<br>-នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល | |

| | | | | |
|---|---|---|---|---|
| | | | ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿង ក្តី និង ភស្តុតាងហើយនោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគី នូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅ ពេលក្រោយ ។(មាត្រា ១០៧)<br>-ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុ ផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារ ខ្លួនថ្មីបានទៀតទេ លើកលែងតុលាការចង់បានភស្តុតា បន្ថែម។(មាត្រា ១០៨)<br>**ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា**<br>- ចៅក្រមបំពេញភារកិច្ចតុលាការ និងរដ្ឋបាល។ ចៅក្រម ត្រូវត្រួតពិនិត្យ និង ណែនាំ ការងាររបស់បុគ្គលិកតុលាការ ឬបុគ្គលិកអយ្យការ ដោយវិរិយភាព( មាត្រា ៣២)<br>-តុលាការមានប្រព័ន្ធ និងការរៀបចំ ដើម្បីធានានូវការ ប្រើប្រាស់ ឱ្យមានប្រសិទ្ធភាព ដោយចៅក្រម និង ព្រះរាជអាជ្ញា( មាត្រា ៣១ និងមាត្រា ៣៣) | |
| | | **ស្តង់ដាទី ៩:** ត្រូវបានគេ យកចិត្ត ទុកដាក់ដោយស្មើ ភាព | **រដ្ឋធម្មនុញ្ញ**<br>សិទ្ធិរបស់បុគ្គលត្រូវបានការពារដោយស្មើភាពគ្នាចំពោះមុខ ច្បាប់។(មាត្រា ៣១)<br>**ក្រមនីតិវិធីរដ្ឋប្បវេណី**<br>-ជនគ្រប់រូបមានសិទ្ធិទទួលបាននូវការជំនុំជំរះក្នុងរឿងក្តី រដ្ឋប្បវេណី(មាត្រា ២) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និង ត្រូវបានការពារដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដោយ គ្មានការរើសអើង។(មាត្រា ២-១-២ , មាត្រា ៧ និង មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)** |

| | | | | |
|---|---|---|---|---|
| | | | -សិទ្ធិរបស់ភាគីក្នុងការស្នើសុំអ្នកបកប្រែ ក្នុងករណីមិនចេះភាសា ខ្មែរ ( មាត្រា ៥)<br>**-ការលុបចោលនូវប្រាតិភោគ :** តុលាការត្រូវចេញដីកាសម្រេច លុបចោលនូវប្រាតិភោគ ប្រសិនបើអ្នកដែលបានដាក់ប្រាតិភោគ បានបញ្ជាក់នូវការ រលត់នៃហេតុដែលត្រូវដាក់ប្រាតិភោគ ។ ( មាត្រា ៧៣-២)<br>- សិទ្ធិទទួលបានអ្នកបកប្រែប្រសិនបើភាគីមិនយល់ភាសាខ្មែរ ។ ( មាត្រា ៨០-១)<br>**គោលការណ៍ទូទៅនៃការទាញហេតុផលដោយផ្ទាល់មាត់និងការរៀបចំ ( មាត្រា ៨៩-មាត្រា ១០២)**<br>- តុលាការអាចសាកសួរឬឱ្យភាគីបំភ្លឺ ។ ភាគីក៏មានសិទ្ធិឱ្យតុលាការសួរសំណួរចាំបាច់ទៅភាគីម្ខាង ទៀត ។ ( មាត្រា ៩០)<br>- តុលាការមិនអាចយកអង្គហេតុណាដែលភាគីណាមួយមិនបានអះអាងមកធ្វើជាមូលដ្ឋាននៃសាលក្រមបានឡើយ ។ ( មាត្រា ៩៥)<br>- តុលាការអាចបង្គាប់ឱ្យភាគីដាក់ឯកសារត្រៀមនៅពេលធ្វើនីតិវិធីត្រៀមសំរាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាលលមាត់ ។ ( មាត្រា ១០១)<br>**នីតិវិធីត្រៀមសំរាប់ការទាញហេតុផលដោយផ្ទាល់មាត់ ( មាត្រា ១០៣-១១២)**<br>- នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវធ្វើឡើង | -មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង ។ ផលប្រយោជន៏ពិសេសរបស់យុវវ័យ ត្រូវបានការពារ ។ ( មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធមិ ( ១៩៦៦)**<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៏ ឬដើម កំណើតជាតិសាសន៏ ។ ( មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ( ១៩៨៩)**<br>-ការធានានូវសិទ្ធិរបស់កុមារ រួម ទាំងសិទ្ធិមានអ្នកបកប្រែ ។ ( មាត្រា ២-១ , មាត្រា ៤០-២-ខ-vi)<br>**អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការ រើសអើងប្រឆាំងនឹងស្ត្រីភេទ ( ១៩៧៩)**<br>-ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំង អស់នៃនីតិវិធីក្នុងតុលាការ និងវិធានការសមរម្យ ដើម្បី លុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។ ( មាត្រា ១៥-១ , មាត្រា ១៥-២ និងមាត្រា ១៦-១) |

| | | | | |
|---|---|---|---|---|
| | | | នៅកាលបរិច្ឆេទដែលភាគីសងខាងអាចចូលរួមបាន ។ ( មាត្រា១០៥)<br>-នៅពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយបានបញ្ចប់ការរៀបចំចំណុចវិវាទនៃរឿង ក្តី និង ភស្តុតាងហើយនោះតុលាការត្រូវធ្វើការបញ្ជាក់ជាមួយភាគី នូវអង្គហេតុដែលនឹងត្រូវបំភ្លឺនៅពេលពិនិត្យភស្តុតាងនៅ ពេលក្រោយ ។ ( មាត្រា ១០៧)<br>-ក្រោយពីបានបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុ ផលហើយ ភាគីមិនអាចដាក់មធ្យោបាយតទល់ ឬ ការពារ ខ្លួនថ្មីបានទៀតទេ លើកលែងតុលាការចង់បានភស្តុតា បន្ថែម ។ ( មាត្រា ១០៨) | |
| | | **ស្តង់ដាទី11:** តុលាការត្រូវធានាដល់សាធារណជន នូវតម្លាភាព និងការអាច ប្រើប្រាស់បាន | **ក្រមនីតិវិធីរដ្ឋប្បវេណី**<br>-ជនគ្រប់រូបមានសិទ្ធិទទួលបាននូវការជំនុំជំរះក្នុង រឿងក្តីរដ្ឋប្បវេណី ( មាត្រា ២)<br>-សវនាការចំពោះមុខភាគី : តុលាការត្រូវគោរព គោលការណ៍ ចំពោះមុខ ។ ( មាត្រា ៣)<br>-តុលាការត្រូវធានាឱ្យបណ្តឹងរដ្ឋប្បវេណី ប្រព្រឹត្តទៅដោយ មាន ភាពយុត្តិធម៌ និងឆាប់រហ័ស ។ ( មាត្រា ៤)<br>-សិទ្ធិរបស់ភាគីក្នុងការស្នើសុំអ្នកបកប្រែ ក្នុងករណីមិន ចេះភាសា ខ្មែរ ( មាត្រា ៥)<br>- អានុភាពនៃការបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញ ហេតុផល ។ ( មាត្រា ១០៨) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈ ( មាត្រា ១០)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោ បាយ (១៩៦៦)**<br>-ភាពស្មើគ្នានៅក្នុងតុលាការ រួមទាំងសិទ្ធិស្មើគ្នានៅក្នុង តុលាការ និងសិទ្ធិទទួលបានព័តិមាននៅក្នុងភាសាដែល អាចធ្វើបាន ។ ( មាត្រា ១៤-៣-ក) |

| | | | | |
|---|---|---|---|---|
| | | | **កាលបរិច្ឆេទនិងកំឡុងពេល ( មាត្រា ២៤០-២៤៥)**<br>- តុលាការត្រូវកំណត់កាលបរិច្ឆេទ តាមពាក្យសុំ ឬ ដោយឆន្ទានុសិទ្ធិ  ហើយភាគីត្រូវបានជូនដំណឹង អំពីកាលបរិច្ឆេទ ។<br>**ការបញ្ជូន( មាត្រា២៤៦-២៥៨)**<br>- លើកលែងតែមានច្បាប់ចែងផ្សេង ការបញ្ជូន ត្រូវធ្វើនៅលំ នៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន ។ ប៉ុន្តែ ចំពោះការបញ្ជូនទៅអ្នកតំណាងដែលច្បាប់បានកំណត់វិញ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់សាមីខ្លួនបាន ។ចំពោះការបញ្ជូនដែលត្រូវធ្វើនៅបរទេស តុលាការត្រូវប្រគល់កិច្ចការនេះឱ្យក្រសួងឬ ស្ថាប័ន ដែលមានសមត្ថកិច្ចនៃប្រទេសនោះ ឬ ឯកអគ្គរាជទូត ឬ ភារធារី ឬ កុងស៊ុល របស់ព្រះរាជាណាចក្រកម្ពុជាប្រចាំប្រទេសនោះ ឱ្យធ្វើបាន ។ ( មាត្រា ២៤៦- ២៥៧)<br>- ការបញ្ជូនអាចធ្វើផងដែរតាមរយៈការចុះផ្សាយជាសាធារណៈនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ។ ការផ្សាយជាសាធារណៈត្រូវបិទនៅលើកន្លែងបិទប្រកាសពត៌មានតុលាការ ។<br>-ការទាមទារមើលសំណុំរឿងនៃបណ្តឹង: ភាគីនៃបណ្តឹង និងតតិយជនដែលធ្វើសេចក្តីបញ្ជាក់ដំបូងអំពីការពាក់ព័ន្ធនឹងផលប្រយោជន៏ក្នុងបណ្តឹង អាចទាមទារមើលសំណុំ | |

| | | | | |
|---|---|---|---|---|
| | | | រឿង ថតចម្លងសំណុំរឿង ឱ្យប្រគល់ ឯកសារចម្លងយថាភូត ឯកសារចមង្ល ដែលមានសេចកីប្ដ ញ្ជា ក់ ឬ ឯកសារដកស្រង់នៃសំណុំរឿង ឬ អាចទាមទារ ឱ្យប្រគល់លិខិតបញ្ជាក់ អំពីចំណុចដែលពាក់ព័ន្ធនឹង បណ្ដឹងពីតុលាការបាន ដោយបង់។ ក្រឡាបញ្ជីត្រូវបញ្ជាក់ ថាជាឯកសារចម្លងយថាភូត ឯកសារចម្លងដែលមាន សេចក្ដីបញ្ជាក់ ឬ ឯកសារដកស្រង់ ហើយនិង ចុះហត្ថលេខា ។ ( មាត្រា ២៥៨) | |
| រដ្ឋបាល | | | ត្រូវពន្យល់ឱ្យបានពិស្ដារ នៅពេលមានច្បាប់ពិសេស | |
| ពាណិជ្ជកម្ម | | | ត្រូវពន្យល់ឱ្យបានពិស្ដារ នៅពេលមានច្បាប់ពិសេស | |
| សង្គម | | | ត្រូវពន្យល់ឱ្យបានពិស្ដារ នៅពេលមានច្បាប់ពិសេស | |

## ដំណាក់កាលនៃដំណើររឿងក្តី

## ដំណាក់កាលទី៥. សវនាការរឿងក្តី

| ប្រភេទ រឿងក្តី | និសដៅ | ស្តង់ដា | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់ និង បទបញ្ញត្តិជាតិ | គោលការណ៍/ លក្ខណៈវិនិច្ឆ័យ ចេញពីច្បាប់ និង បទបញ្ញត្តិអន្តរជាតិ |
|---|---|---|---|---|
| **ទូទៅ** | -តុលាការ ត្រូវតែជាកន្លែងដែលប្រជាពល រដ្ឋអាចប្រើប្រាស់បាន<br>-តុលាការ មានដំណើរការប្រកបដោយ តម្លាភាព<br>-ចៅក្រមសម្រេចសេចក្តី ដោយឯករាជ្យ<br>-មន្ត្រីតុលាការ ត្រូវមានជំនាញវិជ្ជាជីវៈ និងមានការយល់ដឹងគ្រប់គ្រាន់<br>-គូវិវាទមានតំណាងដែលមានប្រសិទ្ធភាព<br>-តុលាការមានដំណើរការប្រកបដោយសមត្ថភាព និងប្រសិទ្ធភាព | **ស្តង់ដាទី5 :** តុលាការមាន សមត្ថកិច្ច | - តុលាការត្រូវបានរៀបចំឡើង ដើម្បីឱ្យពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋអាចចុះ បញ្ជី និងអាចតាមដានបាន (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៥0 និង មាត្រា ៧៥ , និងក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦)<br>- តុលាការមានបុគ្គលិកដែលមានសមត្ថភាព អាចចាត់ចែង រឿងក្តី ដើម្បីកំណត់ បញ្ហាឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៤៧-៣៦៤ និងក្រម នីតិវិធីរដ្ឋប្បវេណី គន្ថី ទី ២ ជំពូកទី ៥ : ការសម្រេចសេចក្តី)<br>-តុលាការត្រូវរៀបចំយ៉ាងណាអោយមានការចេញសេចក្តីសំរេចឱ្យឆាប់រហ័សនិងការបិទសំណុំរឿងដោយត្រឹម ត្រូវ (ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣៥៨, ៣៧៦, ៣៨១ និងមាត្រា ៣៨២ , ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ២៦៤ , គន្ថីទី ៣ ជំពូកទី ១ (បទបញ្ញត្តិទូទៅ) និងជំពូកទី ២ (បណ្តឹងឧទ្ធរណ៍) , មាត្រា ៣៧៦, | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធមនុស្ស (១៩៤៨)**<br>-ដំណោះស្រាយដែលមានប្រសិទ្ធិភាព និងយុត្តិធម៌ ព្រមទាំងសវនាការ ជាសាធារណៈ។ (មាត្រា៨ -មាត្រា១០)<br>**កតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និងគ្មានការរើសអើង។ ផលប្រយោជន៍ពិសេសរបស់យុវវ័យត្រូវបានការពារ។ (មាត្រា ១៤-១)<br>**គោលការណ៍ជាមូលដ្ឋាន ស្តីពីឯករាជ្យភាពក្នុងប្រព័ន្ធតុលាការ ឆ្នាំ ១៩៨៥**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និងបុគ្គល។ នីតិវិធីត្រូវតែដំណើរការដោយយុត្តិធម៌។ ចៅក្រមត្រូវមានសេរីភាពក្នុងការបង្កើតសមាគម។ អាណត្តិរបស់ចៅក្រម ត្រូវតែធានាដោយច្បាប់គ្រប់គ្រាន់។ |

| | | | | |
|---|---|---|---|---|
| | | | ៣៨១, ៣៨២ និងមាត្រា ៣៨៦ )<br>-ចៅក្រមបំពេញភារកិច្ចតុលាការ និងរដ្ឋបាល ។ ចៅក្រម ត្រូវត្រួតពិនិត្យ និង ណែនាំ ការងាររបស់បុគ្គលិកតុលាការ ឬបុគ្គលិកអយ្យការ ដោយវិរិយភាព ( ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣២)<br>-តុលាការមានប្រព័ន្ធ និងការរៀបចំ ដើម្បីធានានូវការប្រើប្រាស់ ឱ្យមានប្រសិទ្ធភាព ដោយចៅក្រម និងព្រះរាជអាជ្ញា ( ក្រមសីលធម៌ ចៅក្រម និងព្រះរាជអាជ្ញា មាត្រា ៣១ និងមាត្រា ៣៣) | ( កឋាខ័ណ្ឌទី ៣-៦-៩-១១)<br>**គោលការណ៍ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា (១៩៩០)**<br>-ភាពមិនលំអៀងនៃការជ្រើសរើសព្រះរាជអាជ្ញា និងការបណ្តុះបណ្តាលព្រះរាជអាជ្ញាដែលត្រឹមត្រូវ ។ ព្រះរាជអាជ្ញាត្រូវបំពេញតួនាទីដោយវិជ្ជាជីវៈ និងផ្តល់សេវាសមហេតុសមផល ។ ស្ថាប័នអយ្យការត្រូវតែដាច់ដោយឡែកពីតុលាការ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែលច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារការគោរពសិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ភស្តុតាងដែលខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ២-៣-៦-១០-១៦)<br>**គោលការណ៍បឺងហ្កាឡូ ស្តីពីក្រមសីលធម៌របស់ចៅក្រម (២០០២)**<br>-ការបំពេញមុខងារនៅក្នុងស្ថាប័នតុលាការ ត្រូវតែមានសមត្ថភាព និងវិរិយភាព ។ ( តម្លៃទី ៦) |
| | | **ស្តង់ដាទី 6 :** តុលាការ ឯករាជ្យ | **រដ្ឋធម្មនុញ្ញ**<br>អំនាចតុលាការជាអំនាចឯករាជ្យ ( មាត្រា ១២៨-ថ្មី-១) | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធម៌ និងជាសាធារណៈដោយតុលាការ ឯករាជ ។ ( មាត្រា ១០) |

| | | | | |
|---|---|---|---|---|
| | | | **ក្រមសីលធមិរបស់ចៅក្រម និង ព្រះរាជអាជ្ញា**<br>- តុលាការត្រូវតែឯករាជ្យ (ជំពូកទី ២-មាត្រា ២-៦-គោលការណ៏ឯករាជ្យ) | **គោលការណ៏ជាមូលដ្ឋានស្ដីពីឯករាជ្យភាពរបស់តុលា ការ (១៩៨៥)**<br>-ឯករាជ្យភាពរបស់តុលាការត្រូវបានធានា មិនត្រូវបានមានការជ្រៀតជ្រែក ការប្រើប្រាស់នូវនីតិវិធីច្បាប់ ត្រូវបានផ្ដល់ឱ្យនូវធនធានគ្រប់គ្រាន់ ការជ្រើសរើស និងការបណ្ដុះបណ្ដាលដោយត្រឹមត្រូវ ធានានូវអាណត្តិរបស់ចៅក្រម ការតំឡើងឋានៈ ដោយមិនលំអៀង ការចាត់ចែងរឿងក្ដីផ្ទៃក្នុង និងតុលាការ ត្រូវប្រកាន់ភ្ជាប់នូវគោលការណ៏សំងាត់វិជ្ជាជីវៈ និងមានអភ័យឯកសិទ្ធីបុគ្គល។ (កឋាខ័ណ្ឌទី ១-៤-៥- ៧-៨-១០-១២-១៥-១៦)<br>**គោលការណ៏ណែនាំស្ដីពីតួនាទី របស់ព្រះរាជអាជ្ញា (១៩៩០)**<br>-ព្រះរាជអាជ្ញាត្រូវបានការពារ នៅពេលត្រូវបានគំរាមកំហែងក្នុងពេលបំពេញការងារ មានសិទ្ធិចូលរួមក្នុងសមាគម។ ស្ថាប័នអយ្យការត្រូវតែដាច់ដោយឡែកពីតុលាការ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែលច្បាប់ផ្ដល់អោយ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារការគោរពសិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ |

| | | | | |
|---|---|---|---|---|
| | | | | ភស្តុតាងដែលខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ៤-៥-៦-៩-១០-១៦) |
| | | **ស្តង់ដាទី 7 :** តុលាការមិន លំអៀង | **រដ្ឋធម្មនុញ្ញ**<br>-អំនាចតុលាការ ធានារក្សាអនាគតិ និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ( មាត្រា ១២៨-ថ្មី-២)<br>**ក្រមសីលធមិរបស់ចៅក្រម និង ព្រះរាជអាជ្ញា**<br>- ចៅក្រម គួរតែមាន ទាំងក្នុង និង ក្រៅតុលាការ នូវឥរិយាបថមិន លំអៀង ( ជំពូកទី ២-មាត្រា ៧ មាត្រា ១៧-គោលការណ៍មិនលំអៀង) | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធិមនុស្ស ( ១៩៤៨)**<br>-សវនាការដោយយុត្តិធមិ និងជាសាធារណៈដោយ តុលាការ ឯករាជ ។ ( មាត្រា ១០)<br>**គោលការណ៍ជាមូលដ្ឋានស្តីពីឯករាជ្យភាពរបស់តុលា ការ ( ១៩៨៥)**<br>-តុលាការមិនត្រូវបាន មានការជ្រៀតជ្រែក , ការប្រើប្រាស់នូវនីតិវិធីច្បាប់ និងធានានូវដំណើរការក្តី ដោយយុត្តិធមិ និងសិទ្ធិរបស់ភាគី ។ ( កឋាខ័ណ្ឌទី ២-៦)<br>**គោលការណ៍ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា ( ១៩៩0)**<br>-ព្រះរាជអាជ្ញាត្រូវបានការពារ នៅពេលត្រូវបានគំរាម កំហែងក្នុងពេលបំពេញការងារ មានសិទ្ធិចូលរួមក្នុង សមាគម ។ ( កឋាខ័ណ្ឌទី ៤-៥-៦-៧-៨) |
| | | **ស្តង់ដាទី 8:** ត្រូវបានគេ យកចិត្តទុកដាក់ដោយស្មើ ភាព | **ក្រមសីលធមិរបស់ចៅក្រម និង ព្រះរាជអាជ្ញា**<br>- នៅពេលដំណើរការនីតិវិធី ចៅក្រម ត្រូវបង្ហាញ នូវភាពហ្មត់ចត់ គោរពពេលម៉ោងធ្វើការ អត់ធ្មត់ ចេះគួរសម មានសីលធមិ និងយុត្តិធមិនៅពេល បំពេញកិច្ចការតុលាការ ។ ( ជំពូក ៣-មាត្រា ៨) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ( ១៩៤៨)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ និង ត្រូវបានការពារដោយស្មើភាពគ្នាចំពោះមុខច្បាប់ ដោយ គ្មានការរើសអើង ។ ( មាត្រា ២-១-២ , មាត្រា ៧ និង មាត្រា ៨)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ( ១៩៦៦)** |

| | | | | |
|---|---|---|---|---|
| | | | | -មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និង គ្មានការរើសអើង។ ផលប្រយោជន៍ពិសេសរបស់យុវវ័យ ត្រូវបានការពារ។ ( មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦) <br> **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ (១៩៦៦)** <br> -វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើម កំណើតជាតិសាសន៍។ ( មាត្រា ២-២) <br> **អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)** <br> -ការធានានូវសិទ្ធិរបស់កុមារ និងសិទ្ធិរបស់កុមារដែល ត្រូវបានចោទប្រកាន់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ រួម ទាំងសិទ្ធិមានអ្នកបកប្រែ។ ( មាត្រា ២-១ , មាត្រា ៤០-២-ខ-vi) <br> **អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការ រើសអើង ប្រឆាំងនឹងស្ត្រីភេទ (១៩៧៩)** <br> -ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំង អស់នៃនីតិវិធីក្នុងតុលាការ និងវិធានការសមរម្យ ដើម្បី លុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ។ ( មាត្រា ១៥-១ , មាត្រា ១៥-២ និងមាត្រា ១៦-១) <br> **គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា- ក្នុង នីតិវិធីព្រហ្មទណ្ឌ (១៩៩០)** |

| | | | | |
|---|---|---|---|---|
| | | | | - ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទី យ៉ាងសកម្មក្នុងរឿងព្រហ្មទណ្ឌ ដែល ច្បាប់ផ្តល់អោយ។ ព្រះរាជអាជ្ញា និង ស្ថាប័នអយ្យការ ត្រូវបំពេញតួនាទី ដោយ ត្រឹមត្រូវ និងការពារ ការគោរព សិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ ភស្តុតាងដែល ខុសច្បាប់។ (កឋាខ័ណ្ឌទី ២-៣-៦-១០-១៦) |
| | | **ស្តង់ដាទី១ :** ទទួលនូវការកាត់សេចក្តី ដោយយុត្តិធម៌ | **រដ្ឋធម្មនុញ្ញ**<br>-សវនាការត្រូវធ្វើឡើងដោយផ្អែកលើច្បាប់និង បទបញ្ញត្តិជាធរមាន។ (មាត្រា ១២៩)<br>**ក្រមសីលធម៌របស់ចៅក្រម និង ព្រះរាជអាជ្ញា**<br>- ចៅក្រមមិនគួរជំនុំជំរះរឿងក្តីណា ដែលមាន មេធាវីមានទំនាក់ទំនងជិតស្និទ្ធជាលក្ខណៈបុគ្គល ជាមួយខ្លួនឡើយ។ (មាត្រា១០)<br>- ចៅក្រមមិនត្រូវមានអត្ថប្រយោជន៍ហិរញ្ញវត្ថុ ឬ អត្ថប្រយោជន៍អ្វីផ្សេងទោះដោយផ្ទាល់ក្តី ឬដោយ ប្រយោលក្តីនៅក្នុងរឿងក្តីដែលខ្លួនកាន់។ (មាត្រា ១៤)<br>- ចៅក្រមត្រូវធានាថា ខ្លួនបំពេញកិច្ចការ តុលាការ ឬអយ្យការប្រកបដោយវីរិយភាព។ (មាត្រា ២៩)<br>- កិច្ចការតុលាការ ឬអយ្យការរបស់ចៅក្រមមាន អាទិភាពជាងកិច្ចការដទៃ។ ចៅក្រមគួរមានពេល វេលាគ្រប់ គ្រាន់ដើម្បី បំពេញ ភារកិច្ចអោយ បានល្អ។ | **កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-សិទ្ធិមានវត្តមានក្នុងសវនាការ សិទ្ធិការពារខ្លួន និង សិទ្ធិមានមេធាវី។ (មាត្រា ១៤-៣-ឃ)<br><br>**គោលការណ៍ណែនាំស្តីពីតួនាទីរបស់ព្រះរាជអាជ្ញា- ក្នុង នីតិវិធីព្រហ្មទណ្ឌ (១៩៩០)**<br>- ការតម្លើងឋានៈព្រះរាជអាជ្ញា ត្រូវផ្អែកលើ កត្តា សត្យានុម័ត និងត្រូវសំរេចតាមនីតិវិធីត្រឹមត្រូវ និងមិនលំអៀង។ (កឋាខ័ណ្ឌទី ៧) |

| | | | | |
|---|---|---|---|---|
| | | | (មាត្រា ៣១)<br>- ចៅក្រមត្រូវបំពេញការងារតុលាការ និង ការងាររដ្ឋបាល ។ ចៅក្រមត្រូវតែគ្រប់គ្រង និងបង្ហាត់បង្រៀននូវការងារ របស់ បុគ្គលិកតុលាការ និង ព្រះរាអាជ្ញាដោយវិរយភាព (មាត្រា ៣២) | |
| **ព្រហ្មទណ្ឌ** | | **ស្តង់ដាទី 2 :** មានឱកាសស្មើៗគ្នាក្នុងការការពារខ្លួន | **ក្រមនីតិវិធីព្រហទណ្ឌៈ**<br>**-ការចូលខ្លួនរបស់ជនជាប់ចោទ:** នៅក្នុងដំណើរការសវនាការ ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅក្នុងសវនាការដោយផ្ទាល់ ឬដោយមានកងកម្លាំងអម ។ (មាត្រា ៣០០, មាត្រា ៣០២, មាត្រា ៣០៣)<br>- **ជំនួយការមេធាវី** ត្រូវតែមានដាច់ខាតនៅក្នុងករណីបទឧក្រិដ្ឋ និងករណីជនជាប់ចោទជាអនីតិជន ។ (មាត្រា ៣០១)<br>- **សិទ្ធិរបស់ជនជាប់ចោទក្នុងការជ្រើសរើសមេធាវី** តាមការសំរេចចិត្តរបស់ខ្លួនឬការចាត់តាំងតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ។ (មាត្រា ៣០៤-១-៣)<br>- ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់ជនជាប់ចោទអំពីរឿងហេតុចោទប្រកាន់និងបទល្មើស ។ (មាត្រា ៣០៤-១-២) | **សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស (១៩៤៨)**<br>- ដំណោះស្រាយមានប្រសិទ្ធិភាព ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ឬការនិរទេសខ្លួនលុះត្រាណាតែមានច្បាប់អនុញ្ញាតិ និងការគោរពសិទ្ធិឯកជន ។ (មាត្រា ៨ មាត្រា ៩ មាត្រា ១២)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និងគ្មានការរើសអើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យត្រូវបានការពារ ។ (មាត្រា ១៤-១ , មាត្រា ១៤-៣-ច និងមាត្រា ២៦)<br>**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (១៩៦៦)**<br>-វិធានការពិសេសដើម្បីធានានូវពូជសាសន៍ ឬដើមកំណើតជាតិសាសន៍ ។ (មាត្រា ២-២)<br>**អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (១៩៨៩)** |

| | | | | |
|---|---|---|---|---|
| | | | | -ការធានានូវសិទ្ធិរបស់កុមារ និងសិទ្ធិរបស់កុមារដែលត្រូវបានចោទប្រកាន់ថាបានបំពានច្បាប់ព្រហ្មទណ្ឌ រួមទាំងសិទ្ធិមានអ្នកបកប្រែ ។ ( មាត្រា ២-១ , មាត្រា ៤០-២-ខ-vi)<br>**អនុសញ្ញាអន្តរជាតិស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើង ប្រឆាំងនឹងស្ត្រីភេទ ( ១៩៧៩)**<br>-ស្ត្រីត្រូវមានសមភាពស្មើគ្នានៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីក្នុងតុលាការ និងវិធានការសមរម្យ ដើម្បីលុបបំបាត់ការរើសអើងប្រឆាំងនឹងស្ត្រីភេទ ។ ( មាត្រា ១៥-១ , មាត្រា ១៥-២ និងមាត្រា ១៦-១) |
| | | **ស្តង់ដាទី 5 :** តុលាការមានសមត្ថកិច្ច | **ក្រមនីតិវិធីព្រហ្មទណ្ឌៈ**<br>**សមត្ថកិច្ចរបស់សាលាដំបូង( មាត្រា ២៨៩)**<br>- សាលាដំបូងជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និង បទលហុ ។ សាលាដំបូងសម្រេចជាក្រុមសមូហភាពដែលមានចៅក្រម ៣ (បី) រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និង បទលហុដែលជាប់ទាក់ទង ។<br>-សាលាដំបូងសម្រេចជាចៅក្រមទោលចំពោះបទមជ្ឈិម និងបទលហុ ។<br>**វិវាទសមត្ថកិច្ចរវាងសាលាដំបូង ( មាត្រា ២៩០)**<br>- ក្នុងករណីដែលមានតុលាការពីរ ឬច្រើន ដែលស្ថិតនៅក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយបានទទួលពាក្យ ប្តឹងលើរឿងតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ | **សេចក្តីប្រកាសជាសាកលស្តីពី សិទ្ធមនុស្ស ( ១៩៤៨)**<br>-ដំណោះស្រាយដែលមានប្រសិទ្ធិភាព និងយុត្តិធម៌ ព្រមទាំង សវនាការ ជាសាធារណៈ ។ ( មាត្រា៨ -មាត្រា១០)<br>**កតិកសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (១៩៦៦)**<br>-មនុស្សគ្រប់រូបមានសិទ្ធិស្មើភាពគ្នាចំពោះមុខច្បាប់ ហើយត្រូវបានការពារដោយច្បាប់ ដោយស្មើភាពគ្នា និងគ្មានការរើសអើង ។ ផលប្រយោជន៍ពិសេសរបស់យុវវ័យត្រូវបានការពារ ។ ( មាត្រា ១៤-១)<br>**គោលការណ៍ជាមូលដ្ឋាន ស្តីពីឯករាជ្យភាពក្នុងប្រព័ន្ធតុលាការ ឆ្នាំ ១៩៨៥**<br>-តុលាការត្រូវមានយុត្តាធិការទៅលើអង្គសេចក្តី និង |

| | | | | |
|---|---|---|---|---|
| | | | ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកលើសំណុំរឿង ។<br>- វិវាទសមត្ថកិច្ចដែនដី រវាងតុលាការច្រើនដែលមានថ្នាក់ស្មើគ្នា ត្រូវសម្រេច ដោយប្រធានតុលាការជាន់ខ្ពស់ ។ ការសម្រេចនេះ បិទផ្លូវតវ៉ា ។<br>**ការពិភាក្សាដេញដោល ( មាត្រា ៣១៦-មាត្រា៣៤៦)**<br>- **សាធារណៈភាពនៃការពិភាក្សាដេញដោល និងការដឹកនាំសវនាការ:** ប្រធានសវនាការ ដឹកនាំ សវនាការ ។ សវនាការត្រូវធ្វើជាសារធារណៈលើកលែង តែមានច្បាប់ចែងផ្សេងពីនេះ ។ មេធាវីមានសិទ្ធិមើលសំណុំរឿងនៅ ការិយាល័យក្រឡាបញ្ជីមុនសវនាការ ។ ( មាត្រា ៣១៦-មាត្រា ៣២០)<br>- **វិធាននៃភស្តុតាង:** តុលាការសំអាងនៅក្នុងសេចក្តីសម្រេចរបស់ខ្លួនតែទៅលើភស្តុតាងដែលមាននៅក្នុងសំណុំរឿងឬដែលត្រូវគេយកមកបង្ហាញនៅពេលសវនាការប៉ុណ្ណោះ ។ ( មាត្រា ៣២១)<br>- **ដំណើរការនៃការពិភាក្សាដេញដោល:** តុលាការត្រូវធានាថាសវនាការប្រព្រឹត្តទៅដោយត្រឹមត្រូវនិងយុត្តិធម៌ ហើយសិទ្ធិរបស់ភាគីត្រូវបានគោរព និង ការពារដោយច្បាប់ ។ ( មាត្រា ៣២២-មាត្រា ៣៤១)<br>- **អញ្ញត្រកម្ម:** តុលាការដែលទទួលបណ្តឹងអាជ្ញាមានសមត្ថកិច្ចដើម្បីសំរេចអំពីគ្រប់អញ្ញត្រកម្មទាំងអស់ | បុគ្គល ។ នីតិវិធីត្រូវតែដំណើរការដោយយុត្តិធម៌ ។ ចៅក្រមត្រូវមានសេរីភាពក្នុងការបង្កើតសមាគម ។ អាណត្តិរបស់ចៅក្រម ត្រូវតែធានាដោយច្បាប់គ្រប់គ្រាន់ ។ ( កឋាខ័ណ្ឌទី ៣-៦-៩-១១)<br>**គោលការណ៏ណែនាំស្តីពីតួនាទី របស់ព្រះរាជអាជ្ញា ( ១៩៩០)**<br>- ស្ថាប័នអយ្យការត្រូវតែដាច់ដោយ ឡែកពីតុលាការ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីយ៉ាងសកម្មក្នុង រឿងព្រហ្មទណ្ឌ ដែល ច្បាប់ផ្តល់អោយ ។ ព្រះរាជអាជ្ញា និងស្ថាប័នអយ្យការ ត្រូវបំពេញតួនាទីដោយត្រឹមត្រូវ និងការពារការគោរពសិទ្ធិមនុស្ស យកចិត្តទុកដាក់លើបទល្មើសព្រហ្មទណ្ឌ ដែលប្រព្រឹត្ត ដោយមន្ត្រីសាធារណៈ និងបដិសេធនូវរាល់ភស្តុតាងដែលខុសច្បាប់ ។ ( កឋាខ័ណ្ឌទី ១០-១៦) |

| | | | | |
|---|---|---|---|---|
| | | | ដែលលើកឡើងដោយភាគី លើកលែងតែច្បាប់បាន បញ្ញត្តផ្សេងពីនេះ។ (មាត្រា ៣៤២-មាត្រា៣៤៦) | |
